ព្រះរាជាណាចក្រកម្ពុជា

ជា ចន្ទ

## សំណួរ_ចម្លើយ

# ភូមិវិទ្យា ១២





ស្របតាមកម្មវិធីសិក្សាថ្មី

# អារម្ភកថា

*សួស្តីប្អូនៗសិស្សានុសិស្សទាំងអស់ជាទីរាប់អាន !!!*

សៀវភៅ **កំណែ សំណួរ-ចម្លើយ ភូមិវិទ្យាថ្នាក់ទី១២** ស្របតាមកម្មវិធីរបស់ក្រសួង អប់រំយុវជន និងកីឡា ដែលប្អូនៗកំពុងកាន់នៅក្នុងដៃនេះ ត្រូវបានរៀបចំឡើងដើម្បីជាជំនួយស្មារតី និងជាឯកសារពិគ្រោះក្នុងការសិក្សារបស់ប្អូនៗ ដែលយើងខ្ញុំបានរៀបរៀងជា កំណែ លំហាត់ សំណួរ-ចម្លើយគ្រប់មេរៀន គ្រប់ជំពូក យើងខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងក្លាយជាមិត្តដ៏ល្អ របស់ប្អូនជាមិនខានឡើយ ទោះជាយើងខ្ញុំខិតខំសំរិតសំរាំងយ៉ាងណា ក៏សៀវភៅនេះនៅមាន កង្វះខាតជាក់ក្នុងចំនុចណាមួយដែរ ។ អាស្រ័យហេតុនេះហើយ យើងខ្ញុំនឹងរង់ចាំទទួលនូវការគន់កែលំអរពីសំណាក់ប្អូនៗសិស្សានុសិស្ស និង ប្រិយមិត្តអ្នកអានទាំងអស់ដោយសេចក្តីរីករាយជាទីបំផុត ។

ជាចុងក្រោយ យើងខ្ញុំសូមជូនពរឱ្យប្អូនៗទាំងអស់ទទួលបាន ជោគជ័យក្នុងការសិក្សា ។

ភ្នំពេញ . ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១

អ្នករៀបរៀង

ជា ចន្ទ

ជំពូកទី១ **លក្ខខណ្ឌសង្គមកម្ពុជា**

មេរៀនទី១ **ជំរឿនប្រជាសាស្ត្រកម្ពុជា**

## សំណួរ

1. តើក្នុងពេលបច្ចុប្បន្ន ប្រទេសកម្ពុជាមានខេត្តចំនួនប៉ុន្មាន ?តើខេត្តណាខ្លះដែលមានក្រុងពីរ ?
2. ហេតុអ្វីបានជាតំបន់វាលរាប និង តំបន់ទន្លេសាបមានប្រជាជនរស់នៅកុះករ ?
3. តើត្រូវធ្វើដូចម្តេច ដើម្បីធ្វើឲ្យប្រជាជនចូលចិត្តទៅរស់នៅតំបន់ខ្ពង់រាប និង តំបន់ភ្នំ ?
4. ចូររៀបរាប់ពីមូលហេតុនៃ ការកើនឡើងនៃប្រជាជនតំបន់ភ្នំ និង តំបន់ខ្ពង់រាប ?
5. ហេតុអ្វីបានជាលទ្ធភាពបង្កកំណើតរបស់ស្ត្រី គឺជាកត្តាកំណត់នៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ?
6. តាមពីរ៉ាមីតរបស់ប្រជាជនកម្ពុជាឆ្នាំ 2008 ហេតុអ្វីបានជាថ្នាក់អាយុ 30-34 ឆ្នាំមានភាពផត ? តើក្រុមអាយុនេះកើតនៅអំឡុងឆ្នាំណា ?តើក្រុមអាយុនេះមានអាយុប៉ុន្មាន ?

ឆ្នាំនៅក្នុងសម័យខ្មែរក្រហមកាន់អំណាច (1975-1979) ?

7. ចូរប្រៀបធៀបចំនួនប្រជាជនសកម្មនៅឆ្នាំ 1998 និង 2008 ?

8. ហេតុអ្វីបានជាប្រើប្រាស់កុមារឲ្យធ្វើការងារ ?

9. តើមនុស្សប្រភេទណាខ្លះ ដែលចាត់ទុកថាជាក្រុមទន់ខ្សោយ ? ហេតុអ្វី ?

## ចំម្លើយ

1. ក្នុងពេលបច្ចុប្បន្នប្រទេសកម្ពុជាមានខេត្តចំនួន 23ខេត្ត ដែលមានក្រុងពីរមាន ខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តបន្ទាយមានជ័យ ។

2. បានជានៅតំបន់វាលរាបនិងតំបន់ទន្លេសាបមានប្រជាជនរស់នៅកុះករ ពីព្រោះតំបន់ទាំងពីរ ជាតំបន់ទំនាបកណ្តាលសំបូរដោយដីមានជីជាតិ សំបូរចំណីអាហារបរិបូរណ៍ (ត្រី សាច់ បន្លែ ផ្លែឈើគ្រប់ប្រភេទ) សម្បូរផ្លូវទឹកងាយស្រួលក្នុងការធ្វើដំណើរនិង ដឹកជញ្ជូនទំនិញទៅមកងាយស្រួលក្នុង ការធ្វើកសិកម្ម និងឧស្សាហកម្មជាលក្ខខណ្ឌដ៏ប្រសើរ សំរាប់ការរស់នៅរបស់មនុស្ស។

3. ដើម្បីធ្វើឲ្យប្រជាជនចូលចិត្តទៅរស់នៅតំបន់ខ្ពង់រាប និង តំបន់ភ្នំ គេត្រូវ ៖

- អភិវឌ្ឍន៍តំបន់ទាំងពីរអោយមានភាពប្រសើរ
- កសាងប្រពន្ធ័ធារាសាស្ត្រ
- បង្កើតហេដ្ឋារចនាសម្ព័ន្ធសង្គម (សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ វត្ត ផ្សារ ស្ពាន )
- បង្កើតទំនប់វារីអគ្គិសនី
- ផ្គត់ផ្គង់ទឹកសំរាប់ប្រើប្រាស់គ្រប់គ្រាន់
- ផ្តល់ដីសំរាប់ធ្វើកសិកម្ម
- ធ្វើការលើទឹកចិត្តដល់ប្រជាជនដែល បានទៅរស់នៅតំបន់ខ្ពង់រាប និងតំបន់ភ្នំ ។

4. រៀបរាប់ពីមូលហេតុ នៃការកើនឡើងនៃប្រជាជននៅតំបន់ភ្នំនឹងខ្ពង់រាបដោយសារ ៖

- តំបន់នោះដីមានជីវជាតិ សំបូរព្រៃឈើ និង សត្វព្រៃ
- មានផ្លូវគមនាគមន៍ងាយស្រួលក្នុងការធ្វើដំណើរ
- តំបន់នោះងាយស្រួលក្នុងការប្រកបមុខរបរ
- តំបន់នោះមានដីធំទូលាយងាយស្រួលក្នុងការ ធ្វើកសិកម្ម ។

5. បានជាលទ្ធិភាពបង្កកំណើតរបស់ស្ត្រី គឺជាកត្តាកំនត់នៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្សពីព្រោះ បើសិនជាលទ្ធិភាពបង្កកំណើតរបស់ស្ត្រីមានកំរិតខ្ពស់ នោះសន្ទស្សន៍ការអភិវឌ្ឍន៍មនុស្សទាប(បញ្ហាចូលរៀនមានកម្រិត អាហារូបត្ថម្ភមិនគ្រប់គ្រាន់ សុខភាពមិនល្អ)។ផ្ទុយទៅវិញ បើសិនជាលទ្ធិភាព បង្កកំណើតរបស់ស្ត្រីមានកម្រិតទាបនោះសន្ទស្សន៍ ការអភិវឌ្ឍន៍មនុស្សកម្រិតខ្ពស់(អត្រាចូលរៀនខ្ពស់ អាហារូបត្ថម្ភគ្រប់គ្រាន់ សុខភាពប្រជាជនល្អប្រសើរ និង មានអាយុវែង )។

6. តាមពីរ៉ាមីតរបស់ប្រជាជនកម្ពុជា2008 ដែលថ្នាក់អាយុ 30-34 ឆ្នាំ មានភាពផត ពីព្រោះប្រជាជននៅក្រុមអាយុនេះទាំងប្រុសនិងស្រីមានចំនួនតិចជាងគេ ដោយសារការថយចុះនូវលទ្ធិភាពបង្កកំនើតរបស់ស្ត្រី និងមរណភាពរបស់កុមារ នៅសម័យខ្មែរក្រហម។ ក្រុមអាយុនេះកើតនៅ ឆ្នាំ1974-1978 ។ ក្រុមអាយុនេះមានអាយុ ពី 1- 5 ឆ្នាំ ។

7. ប្រៀបធៀបចំនួនប្រជាជនសកម្មនៅកម្ពុជាក្នុងឆ្នាំ 1998 និង 2008 មានបុរស និង ស្ត្រីដែលធ្វើការងារ

លើវិស័យការងារទាំងបីគឺ កសិកម្ម ឧស្សាហកម្ម និង សេវាកម្មមានដូចជា៖

- ប្រជាជនដែលធ្វើការក្នុង វិស័យកសិកម្មភាគច្រើនជាស្ត្រី
- នៅឆ្នាំ 1998 និង មានការថយចុះនៅឆ្នាំ 2008។
- ប្រជាជនដែលធ្វើការក្នុង វិស័យឧស្សាហកម្មមានការ
- កើនឡើងគួរអោយកត់សំគាល់គឺ ស្ត្រីមានចំនួនច្រើនជាងបុរស។
- ប្រជាជនដែលធ្វើការក្នុងវិស័យសេវាកម្ម មានចំនួនកើន ឡើងឯចំនួនស្ត្រីវិញថ្វីត្បិតមានចំនួនតិចជាបុរសក៏ដោយ តែបើធៀបទៅនឹង ឆ្នាំ1998 មានសន្ទុះកើនឡើងខ្លាំងជាងបុរស ។
- តំបន់នោះសំបូរធនធានរ៉ែ
- បច្ចុប្បន្នតំបន់នោះមានការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធ( ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ ស្ពាន ផ្សារ ប្រព័ន្ធធារាសាស្ត្រ )
- សំបូរដំណាំឧស្សាហកម្ម ។

8.បានជាប្រើប្រាស់កុមារឲ្យធ្វើការងារ

- កុមារជាមនុស្សទន់ខ្សោយគ្មានកំលាំងតវ៉ា ឬ ប្រកែក បាន
- កុមារមានចំនេះដឹងទាបងាយស្រួលក្នុងការបោកប្រាស់
- ខ្វះកំលាំងពលកម្ម និង ភាពក្រីក្រ ឪពុកម្តាយគាប សង្កត់
- ដោយសារបរិស្ថានជុំវិញ
- ភាពខ្វះខាតរបស់គ្រួសារ
- ដោយសារឪពុកម្តាយខ្វះចំនេះដឹង បង្ខំកូនឲ្យធ្វើការ។

9. មនុស្សប្រភេទដែលចាត់ទុកថាជាក្រុមទន់ខ្សោយ គឺ ស្ត្រីមេម៉ាយ និង ជនពិការ ។ ពីព្រោះ

- ពួកគេមិនបានចូលរួមយ៉ាងសកម្មក្នុង វិស័យកសិកម្ម ឧស្សាហកម្ម និង សេវាកម្ម ។
- មានកំលាំងទន់ខ្សោយ និង គ្មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការធ្វើការធ្ងន់ធ្ងរ។
- ជនពិការមានកាយសម្បទាមិនរឹងមាំ ។

# មេរៀនទី២ បំលាស់លំនៅនៃប្រជាជនកម្ពុជា

## សំណួរ

1. ហេតុអ្វីបានជាបំលាស់ប្តូរទីលំនៅជាបាតុភូតសកល ?
2. តើមានព្រឹត្តិការណ៍អ្វីខ្លះ កើតឡើងនៅពេលដែលខ្មែរក្រហមឡើងអំណាច ?
3. ហេតុអ្វីបានជាមាន ចលនាចំណាកស្រុកនៅរបបខ្មែរក្រហមដូលរលំ?
4. តើចលនាមាតុភូមិនិវត្តន៍ របស់ប្រជាជនកម្ពុជាធ្វើឡើងនៅក្នុងពេលណា ? ហេតុអ្វីបានជាមានចលនានេះ ?តើគេអនុវត្តគោលនយោបាយ ដូចម្តេចខ្លះចំពោះជនទាំងនោះ?
5. ចូររៀបរាប់អំពីចលនាបំលាស់លំនៅផ្ទុយគ្នារវាង ដើមឆ្នាំ1970 និង នៅ ឆ្នាំ1975 ?
6. តើបំលាស់លំនៅកម្ពុជាបច្ចុប្បន្នមានរូបភាពអ្វីខ្លះ?តើរូបភាពណាមួយដែលមានទំហំធំជាងគេ ? ហេតុអ្វី ? តើរូបភាពណាមួយ បណ្តាលអោយមានបញ្ហានគរូបនីកម្ម?

## ចំម្លើយ

1. បានជាបំលាស់ប្តូរទីលំនៅបាតុភូតសកល ពីព្រោះវាកើតមាននៅគ្រប់ប្រទេសទាំងអស់ ក្នុងពិភពលោក មិនថាប្រទេសអ្នកមាន ឬ ប្រទេសអ្នកមានឡើយ ?
2. ព្រឹត្តិការណ៍នៅពេលខ្មែរក្រហមឡើងកាន់អំនាច នៅឆ្នាំ (1975-1979 ) ពួកនេះបានបង្កឲ្យមាន ចលនាបំលាស់លំនៅមួយយ៉ាងធំ គឺប្រជាជនដែលរស់នៅតាមខេត្តក្រុង ត្រូវជន្លៀសចេញទាំងបង្ខំឲ្យទៅរស់នៅទីជនបទ ។ ទន្ទឹមនេះក៏មានមនុស្សជាច្រើនបានសាកល្បងរត់គេចទៅជ្រកកោនក្នុងប្រទេសជិតខាង មុនពេលបិទច្រកព្រំដែន ។
3. បានជាមានចលនាបំណាកស្រុក នៅពេលរបបខ្មែរក្រហមដួលរលំពីព្រោះមានរបបថ្មីមួយបានកើតឡើងគឺសាធារណរដ្ឋប្រជាមានិតកម្ពុជាប្រជាជនមានសេរីភាពប្រជាជនជាច្រើនដែល បានបែកគ្នាបានស្វែងរកក្រុមគ្រួសារ ចលនាបំលាស់លំនៅទៅស្រុក កំនើតវិញ ។
4. មាតុភូមិនិវត្តន៍ជនភៀសខ្លួនកម្ពុជា ធ្វើឡើងនៅពេលដែលមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស២តុលា

1991។ដោយសារការខិតខំប្រឹងប្រែងរបស់អគ្គស្នងការ អង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន បានរកដីសម្រាប់ធ្វើកសិកម្មបានប្រមាណ240000 ហិចតាចែកជូនដល់ជនភៀសខ្លួនទាំងនោះ។គេអនុវត្តគោលនយោបាយដូចជា ផ្តល់លទ្ធិភាពឲ្យជនភៀសខ្លួនទាំងនោះធ្វើការជ្រើសរើសយកដីដាំដុះឬមួយទទួលយកជាលុយ ។

5. រៀបរាប់ពីចលនាបំលាស់លំនៅផ្ទុយគ្នារវាង ដើមឆ្នាំ 1970 និង នៅឆ្នាំ1975 ចលនាបំលាស់លំនៅ នៅដើមឆ្នាំ1970ជាចលនាដែលមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងទៅនឹងប្រជាជនរស់នៅជនបទ ដែលមកជ្រកកោន និងរកការងារធ្វើនៅក្នុងទីក្រុង ។ នៅឆ្នាំ 1975 ជាចលនាជម្លៀសប្រជាជនទាំងអស់ ដែលរស់នៅទីរួមខេត្ត និងទីក្រុងឲ្យទៅរស់នៅជនបទ ។

6. រូបភាពបំលាស់លំនៅ នៅកម្ពុជាបច្ចុប្បន្ន រូបភាពបំលាស់លំនៅ ពីជនបទទៅទីក្រុង បំលាស់លំនៅពីជនបទទៅជនបទ បំលាស់លំនៅពី ទីក្រុងទៅទីក្រុងបំលាស់លំនៅ ពីទីក្រុងទៅជនបទ ។ រូបភាដែលបំលាស់លំនៅច្រើនជាងគេគឺរូបភាពបំលាស់លំនៅពីជនបទ

ទៅជនបទ ។ មូលហេតុវាជាឆ្នាំមួយដែលមានសេដ្ឋកិច្ចកើនឡើងខ្ពស់ ជាពិសេសគឺតំលៃដីឡើងថ្លៃខ្ពស់ ដែលធ្វើឲ្យប្រជាជនធ្វើការលក់ដូរដីពីកន្លែង ដែលមានតំលៃថ្លៃទៅរស់នៅកន្លែងមួយទៀត និងវាជាឆ្នាំមួយ ដែលមានវិបត្តសេដ្ឋកិច្ចតំលៃទំនិញឡើងថ្លៃដែលធ្វើឲ្យមានការប្តូរកន្លែងធ្វើការ ស្វែងរកការងារធ្វើ អសន្តិសុខ ការវិលជួបជុំគ្រួសារ ក្ជនកំព្រាការបាត់បង់ដីធ្លី និង លំនៅដ្ឋាន ។ រូបភាពដែលបណ្តាលអោយមានបញ្ហានគរូបនីយកម្មគឺ រូបភាពបំលាស់លំនៅក្នុងស្រុកពីជនបទទៅទីក្រុង ។

# ចំម្លើយ និង សំណួរបញ្ចប់ជំពូកទី១

i. ចូរគូសសញ្ញា✓ក្នុងប្រអប់ដែលមានចំលើយត្រូវតែមួយគត់

1. ប្រទេសកម្ពុជាមានខេត្តចំនួន

☐ក.22 ☑ខ.23

☐គ.24 ☐ឃ.25

2. ខេត្តដែលមានទីក្រុងចំនួន 2 មានចំនួន

☐ក.2 ☑ខ.3

☐គ.4 ☐ឃ.5

3. ខេត្តដែលស្ថិតនៅតំបន់ទន្លេសាបមានចំនួន

☐ក.5 ☐ខ.6

☐គ.7 ☑ឃ.8

4. ខេត្តដែលស្ថិតនៅជាប់សមុទ្រមានចំនួន

☐ក.2 ☐ខ.3

☑គ.4 ☐ឃ.5

5. រូបភាពបំលាស់លំនៅនៅកម្ពុជាមានច្រើនជាងគេគឺ

☑ក.ជនបទ →ជនបទ ☐ខ.ជនបទ→ទីក្រុង

☐គ.ទីក្រុង →ជនបទ ☐ឃ.ទីក្រុង →ទីក្រុង

6.រូបភាពបំលាស់ប្ដូរលំនៅ ដែលនាំឲ្យមានបញ្ហានគរូបនីយកម្មគឺ

☑ក.ជនបទ → ជនបទ　　☐ខ.ជនបទ → ទីក្រុង

☐គ.ទីក្រុង → ជនបទ　　☐ឃ.ទីក្រុង → ទីក្រុង

II. ចូរបំពេញឃ្លាខាងក្រោមឲ្យបានត្រឹមត្រូវ

1. ចំនួនមនុស្សប្រុសក្នុងចំណោមមនុស្សស្រី 100 នាក់ហៅ **អត្រាភេទ**...............។

2. វិស័យសេដ្ឋកិច្ចទាំងបីគឺ ...**កសិកម្ម** ......**ឧស្សាហកម្ម**......និង...**ពាណិជ្ជកម្ម**.........។

3. ចំពោះបញ្ហាសំខាន់បីដែលបណ្ដាលមកពីចលនាបំលាស់លំនៅពីជនបទទៅទីក្រុងគឺ ...**សេដ្ឋកិច្ច**......**សង្គមកិច្ច** ...និង **វប្បធម្ម**.....................។

4. អក្សរសេរកាត់ជាឡាតាំង " UNHCR" មានន័យពេញលេញគឺ...**អគ្គស្នងការអង្គការសហប្រជាជាតិ**...។

## ចម្លើយ និង សំណួរត្រូវ

1. ហេតុអ្វីបានជានៅវ័យចាស់ប្រជាជនភេទស្រីនៅកម្ពុជាមានកាន់តែច្រើនជាងបុរស ?

**ចម្លើយ** បានជានៅវ័យចាស់ប្រជាជនភេទស្រីនៅកម្ពុជាមាកាន់តែច្រើនជាងបុរស់ ដោយសារមនុស្សប្រុសក្នុងក្រុមមនុស្សអាយុនេះ បានស្លាប់ច្រើនជាងមនុស្សស្រីនៅសម័យខ្មែរក្រហម ។

2. កត្តាសំខាន់ទាំងពីរយ៉ាងដែលធ្វើឲ្យអត្រាចូលរួមសកម្មភាពសេដ្ឋកិច្ច នៅតំបន់ជនបទខ្ពស់ជាងទីប្រជុំជនមានអ្វីខ្លះ?

**ចម្លើយ** កត្តាសំខាន់ទាំងពីរយ៉ាង ដែលធ្វើឲ្យអត្រាចូលសកម្មភាពសេដ្ឋកិច្ច នៅតំបន់ជនបទខ្ពស់ជាងទីប្រជុំដោយសារ ការចូលរួមកម្លាំងពលកម្មក្នុងសកម្មភាពស្រែចំការនៅតំបន់ជនបទមានអត្រាខ្ពស់ទី២សមាមាត្រនៃការចូលរៀននៅតំបន់ជនបទមានអត្រាទាប។

3. ចូររៀបរាប់អំពើមូលហេតុដែលនាំឲ្យមានបំលាស់លំនៅ ? មូលហេតុដែលនាំឲ្យមានបំលាស់លំនៅដោយសារការប្តូរកន្លែងធ្វើការ ស្វែងរកការងារធ្វើ ការ

សិក្សា រៀបអាពាហ៍ពិពាហ៍ គ្រួសារផ្លាស់លំនៅមាតុភូមិនិវត្តន៍ គ្រោះធម្មជាតិអសន្តិសុខ ការបាត់បង់ដីធ្លី និងលំនៅ ។

4. ចូលរៀបរាប់ពីបញ្ហានគរូបនីកម្ម ដែលបណ្តាលមកពីបំលាស់លំនៅពីជនបទទៅទីក្រុង ? បញ្ហានគរូបនីកម្មមានដូចជា ៖ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ថែមទៀត។

# ជំពូកទី២

# ការអភិវឌ្ឍន៍ប្រជាជនមិនស្មើគ្នា

## មេរៀនទី១ ឧសមភាពចំពោះសុខភាព

## សំណួរ

1. ហេតុអ្វីបានជាគេចាត់ទុកជំងឺគ្រុនចាញ់ជាជំងឺឆ្លង ?
2. ខេត្តណាខ្លះ ដែលឆ្លងជំងឺគ្រុនចាញ់ច្រើនជាងគេ ? ហេតុអ្វី ?
3. តើមេរោគអេដស៍ និងជំងឺអេដស៍ខុសគ្នាដូចម្តេច ?
4. តើទ្វីបណាដែលមានអត្រាជំងឺអេដស៍ខ្ពស់ជាងគេ ?
5. តើវ័យណាខ្លះដែលមានជំងឺអេដស៍?ហេតុអ្វីបានជាវ័យ ពី 15 ទៅ 49 ឆ្នាំប្រឈម និង ជំងឺអេដស៍ខ្ពស់ជាងគេ ?
6. តើអេដស៍ឆ្លង និង មិនឆ្លងក្នុងករណីណាខ្លះ?
7. ហេតុអ្វីបានជាប្រទេសកំពុងអភិវឌ្ឍមាន បញ្ហាចោទ អំពីការបរិភោគមិនគ្រប់គ្រាន់ ?

5. តើកង្វះអាហារូបត្ថម្ភបណ្តាលមកពី កង្វះចំណីអាហារ តែមួយមុខ ឬដូចម្តេច ?

6. តើការបំបៅដោះកូនដោយទឹកដោះម្តាយ មានផលប្រយោជន៍យ៉ាងណាខ្លះចំពោះទារក ?

## ចំលើយ

1. បានជាគេចាត់ទុកជំងឺគ្រុនចាញ់ជាជំងឺឆ្លង ពីព្រោះវាជាជំងឺឆ្លងពី មនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមមូសដែកគោលញី ។

2. ខេត្តដែលឆ្លងជំងឺគ្រុនចាញ់ច្រើនជាងគេគឺ ខេត្តរតនគិរីក្រចេះ ព្រះវិហារ ឧត្តរមានជ័យ បាត់ដំបង ពោធិ៍សាត់ប៉ៃលិន ។ មូលហេតុវាជា តំបន់ភ្នំ សំបូរព្រៃឈើ វាជាតំបន់ដីសើមសំបូរទឹកដក់ ជាតំបន់ព្រៃស្តុក ជាតំបន់ដីសើម ប្រជាជនមិនបានយល់ដឹងពីជំងឺគ្រុនចាញ់ ។

3. មេរោគអេដស៍និង ជំងឺអេដស៍ខុសគ្នាត្រង់ ៖ មេរោគអេដស៍ជាមេរោគ ( វីរុស ) ដែលធ្វើអោយប្រពន្ធ័ភាពស៊ាំរបស់សាពាង្គកាយមនុស្សចុះខ្សោយរីឯ (AIDS)ជាប្រជុំរោគសញ្ញា ដែលកើតក្រោយពីប្រពន្ធ័ភាពស៊ាំរបស់សាពាង្គកាយមនុស្សចុះខ្សោយ ។

4. ទ្វីបដែលមានអត្រាជំងឺអេដស៍ខ្ពស់ជាងគេគឺ ទ្វីបអាហ្វ្រិក ។ វ័យដែលមានជំងឺអេដស៍ គឺចាប់ពីវ័យ 15ទៅ 49 ឆ្នាំ ។ ពីព្រោះវ័យនេះជាមនុស្សពេញវ័យ ប្រឡូកក្នុងការរួមភេទច្រើន វ័យនេះភាគច្រើនជាពួកចំណូលស្រុក ប្រើប្រាស់គ្រឿងញៀនដោយប្រើម្ជុលរួមគ្នា ការប្រើប្រាស់គ្រឿងស្រវឹងធ្វើឲ្យបាត់បង់ស្មារតីភ្លេចប្រើស្រោម នៅពេលរួមភេទបណ្តាលឲ្យឆ្លងជំងឺអេដស៍។ អេដស៍ឆ្លង និង មិនឆ្លងក្នុងករណី ៖

❖ករណីឆ្លង

- ការរួមភេទ
- ការប៉ះពាល់ឈាម ប្រើម្ជុល ឬ សឺរាំង
- ឆ្លងពីម្តាយទៅកូន ( ពេលពពោះ សម្រាលនិងពេលបំបៅដោះ ) ចំពោះម្តាយដែលមានផ្ទុកមេរោគអេដស៍
- ការបញ្ចូលឈាមដែលមានផ្ទុកមេរោគអេដស៍

❖ករណីមិនឆ្លង

- តាមរយៈទឹកមាត់
- ការដកដង្ហើម

- ការបរិភោគ ទឹក និងចំណីអាហាររួមគ្នា
- ការប្រើប្រាស់ខោអាវរួមគ្នា
- ការប៉ះអ្នកជំងឺដោយគ្មានដាច់ឈាម
- ការប្រើប្រាស់ប្រដាប់ផ្ទះបាយរួមគ្នា
- ការថើបគ្នា ការរស់នៅជាមួយគ្នា
- គ្រប់សកម្មភាពរស់នៅប្រចាំថ្ងៃ ។

7. បានជាប្រទេសកំពុងអភិវឌ្ឍ មានបញ្ហាចោទអំពីការបរិភោគមិនគ្រប់គ្រាន់ពីព្រោះ ប្រទេសនោះមាន ចំនួនប្រជាជនច្រើន មានកំណើនប្រជាជនខ្ពស់ ផលិតកម្មស្បៀងមានកំណើនយឺត តំរូវការក្នុងការប្រើប្រាស់មានការកើនឡើង ។ ប្រជាជនមានកូនច្រើនមានកូនច្រើនមានជីវភាពក្រីក្រ គ្មានថវិកាសំរាប់ទិញចំណីអាហារបរិភោគ ។

8. កង្វះអាហារូបត្ថម្ភមិនបណ្ដាលមកពី កង្វះចំណីអាហារតែមួយមុខទេ វាអាចបណ្ដាលមកពី ការថែទាំពីមាតាបិតាកង្វះសេវាសុខភាព កង្វះអនាម័យ គ្មានទឹកស្អាតសំរាប់ប្រើប្រាស់ គ្មានបង្គន់សំរាប់ប្រើប្រាស់ និង

មិនត្រឹមតែប៉ុនោះការរស់នៅក៏ត្រូវរស់នៅជុំវិញបរិស្ថានដែលស្អាត។

9. ការបំបៅដោះកូនដោយទឹកដោះម្ដាយ មានផលប្រយោជន៍ជាច្រើនយ៉ាងណាស់ ចំពោះកុមារមានដូចជា៖

- ផ្ដល់ភាពស៊ាំដល់ទារក
- ជួយសម្អាតអាចម៍ព្រៃ ( លាមកខ្មៅដំបូង )
- ផ្ដល់មីក្រូសារជាតិសំខាន់ៗ ដូចជា ជីវជាតិអា ជាតិដែក
- ជួយទប់ស្កាត់កុមារមិនអោយមានប្រតិកម្ម និងការមិនទទួលអាហារបាន
- ផ្ដល់សាធាតុចិញ្ចឹមដែលទារកត្រូវការពិតៗ
- ជួយទារកអោយមានអភិវឌ្ឍន៍ ។

# មេរៀនទី២ វិសមភាពចំពោះការអប់រំ

## សំណួរ

1. ហេតុអ្វីបានជាបានជាគេចាត់ទុកកម្រិតអក្ខរកម្ម ជាសូចនាករដ៏សំខាន់សម្រាប់អភិវឌ្ឍសង្គមជាតិ ?
2. ចាប់ពីឆ្នាំ១៩៩៨ ដល់២០០៨តើកម្រិតអក្ខរកម្មនៅកម្ពុជាលក្ខណៈដូចម្តេច ? ចូលពន្យល់អំពីមូលហេតុ ។
3. តើវិសមភាពនៃអក្ខរភាព មាននៅក្នុងរូបភាពណាខ្លះ ?
4. ហេតុអ្វីបានជាប្រជាជន ដែលរស់នៅទីប្រជុំជនមានកម្រិតអក្ខរភាពខ្ពស់ជាងប្រជាជនជនបទ ?
5. តើអ្នកគិតថា ការចេះភាសាផ្សេងៗទៀតក្រៅពីភាសាជាតិខ្លួន ផ្តល់ផលប្រយោជន៍យ៉ាងណាខ្លះ ចំពោះខ្លួនឯងនិង ចំពោះសង្គមជាតិ ?
6. តើវិសមភាពនៃការចូលរៀនតាមភេទ កើតមានចាប់ពីពេលណា ? ហេតុអ្វី ?
7. ការអប់រំមានឥទ្ធិពលដូចម្តេច ទៅលើអាពាហ៍ពិពាហ៍លទ្ធិភាពបង្កើតកូន និង មរណភាព ។ ចូរពន្យល់បកស្រាយ ។

## ចម្លើយ

1.បានជាគេចាត់ទុកកម្រិតអក្ខរកម្មជាសូចនាករដ៏សំខាន់សម្រាប់អភិវឌ្ឍសង្គមជាតិពីព្រោះកម្រិតអក្ខរកម្មកម្លាំងសម្រាប់កែប្រែសង្គមនិង ជាកត្តាដ៏សំខាន់បំផុតតែមួយគត់សម្រាប់ប្រយុទ្ធប្រឆាំងនឹង ភាពក្រីក្រ ផ្តល់សិទ្ធអំណាចដល់ស្ត្រីការពារកុមារពីការកេងប្រវ័ញ្ច លើកស្ទួយសិទ្ធមនុស្សនិងលទ្ធិប្រជាធិបតេយ្យ ការពារបរិស្ថាននិង សម្រាប់គ្រប់គ្រងការរីកចម្រើនរបស់ពលរដ្ឋលើសពីនេះទៅទៀត វាមានឥទ្ធិពលទៅលើឥរិយាបទប្រជាសាស្ត្រដែលទាក់ទងនឹងអាពាហ៍ពិពាហ៍លទ្ធិភាពបង្កើតកូនមរណភាព បំលាស់លំនៅ ក៏ដូចជាការចូលរួមក្នុងកម្លាំង ពលកម្មថែមទៀតផងទាំងអស់នេះហើយដែលជំរុញឲ្យកម្រិតអក្ខរកម្មជាសូចនាករមួយដ៏សំខាន់នៃការអភិវឌ្ឍសង្គម ។

2.ចាប់ពីឆ្នាំ១៩៩៨ ដល់២០០៨កម្រិតអក្ខរកម្មនៅកម្ពុជាមានសន្ទុះកើនឡើងខ្លាំងពី 5.78 លាននាក់នៅឆ្នាំ1998 ទៅ 8.96 លាននាក់ នៅឆ្នាំ 2008 ដោយសាររាជរដ្ឋាភិបាល និង ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្ត

ទុកដាក់កសាងគ្រឹះស្ថានសិក្សានៅគ្រប់ភូមិស្រុកទូទាំងប្រទេសនិងគ្រប់កំរិតជាន់ថ្នាក់ហើយ បានខិតខំប្រមូលកុមារ កុមារី យុវជន និង យុវនារី អោយបានចូលរៀនគ្រប់ៗគ្នា។

3.វិសមភាពនៃអក្ខរភាព មាននៅក្នុងរូបភាពដូចជា ៖

- វិសមភាពនៃអក្ខរភាព មាននៅក្នុងរូបភាពតាមភេទ
- វិសមភាពនៃអក្ខរភាព រវាងប្រជាជនទីប្រជុំជន និង ជនបទ ។

4.បានជាប្រជាជន ដែលរស់នៅទីប្រជុំជនមានកម្រិតអក្ខរ ភាពខ្ពស់ជាងប្រជាជនជនបទដោយសារ ៖

- តំបន់ជនបទសេដ្ឋកិច្ចពុំមានការលូតលាស់
- ប្រជាជននៅតំបន់ជនបទមានជីវភាពក្រីក្រ
- ឪពុកម្តាយខ្វះចំនេះដឹងមិនយល់ដឹងពីសារៈសំខាន់នៃការសិក្សាមិនបានឲ្យកូនចូលរៀន
- ដោយសារជីវភាពក្រីក្រ ឪពុកម្តាយត្រូវបង្ខំចិត្តទុកកូនឲ្យជួយការងារគាត់
- តំបន់នោះពុំសូវសំបូរសាលារៀន ឬ សាលារៀននៅឆ្ងាយ ពិបាកក្នុងការធ្វើដំណើរ

• ភាពអសន្តិសុខនៅតំបន់ជនបទ
• ប្រជាជននៅជនបទប្រកាន់ភ្ជាប់នូវទំនៀមទំលាប់កូនស្រីមិនត្រូវឲ្យរៀនច្រើន
• គ្មានមធ្យោបាយធ្វើដំណើរ ។

5. ការចេះភាសាផ្សេងៗទៀតក្រៅពីភាសាជាតិខ្លួន ផ្តល់ផលប្រយោជន៍យ៉ាងណាខ្លះ ចំពោះខ្លួនឯង និង ចំពោះសង្គមជាតិ ដូចជា ៖

❖ ចំពោះខ្លួនឯង

• ងាយស្រួលក្នុងការស្វែងរកការងារធ្វើ
• ងាយស្រួលក្នុងការទំនាក់ទំនងជាមួយជនបរទេស
• ងាយស្រួលក្នុងការបន្តការសិស្សនៅបរទេស
• ងាយស្រួលក្នុងការស្វែងរកឯកសារតាម Internet សំរាប់ការសិក្សានៅសាកលវិទ្យាល័យ
• មានចំនេះដឹងទូលំទូលាយពីបញ្ហាសកល

❖ចំពោះសង្គម

• ប្រទេសសំបូរទៅដោយអ្នកចេះដឹង
• ធ្វើឲ្យវិស័យទេសចរណ៍មានភាពរីកចំរើនព្រោះសម្បូរអ្នកបកប្រែ

- ទំនាក់ទំនងខាងពាណិជ្ជកម្មមានភាពរីកចំរើន
- សេដ្ឋកិច្ចមានភាពរីកចំរើនព្រោះ ប្រជាជនសំបូរការងារធ្វើ
- វិស័យអប់រំមានភាពរីកចំរើន ជាពិសេសខាងភាសារអន្តរជាតិ
- បច្ចេកវិទ្យាមានភាពជឿនលឿន ពិសេសខាងផ្នែកកុំព្យូទ័រ ។

6.វិសមភាពនៃការចូលរៀនតាមភេទ កើតមានចាប់ពីពេលកម្រិតមធ្យមសិក្សាបឋមភូមិទៅ ។ ដោយសារតែការឆាប់ឲ្យកូនស្រីចាប់យកមុខរបរចិញ្ចឹមជីវិត ដើម្បីជួយសម្រាលដល់ជីវភាពក្នុងគ្រួសារ(ពិសេសធ្វើជាកម្មការិនីកាត់ដេរ) និង ទំនៀមទម្លាប់ឆាប់ឲ្យកូនស្រីរៀបការ ។

7.ការអប់រំវាមានឥទ្ធិពលខ្លាំងចំពោះ អាពាហ៍ពិពាហ៍លទ្ធិភាពបង្កើតកូន និងមរណភាព ប្រសិនបើស្ត្រី និងបុរសមានការបន្តការសិក្សាបានវែងឆ្ងាយរហូតដល់មហាវិទ្យាល័យនោះពួកគេនិងពន្យាពេលរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងរបស់ពួកគេ នៅពេលដែលពួកគេ

យូរក្នុងការរៀបការនោះវានិងធ្វើឲ្យរយៈពេលមានកូនរបស់ពួកគឺខ្លីព្រោះតែពួកគេរៀបការនូវអាយុច្រើន ។ បន្ថែមពីនេះទៅទៀតនៅពេលពួកគេបានរៀនសូត្របានច្រើននោះពួកគេនិងមានការយល់ដឹងច្រើនពីផលវិបាកនៃការមានកូនច្រើន ហើយវានិងធ្វើឲ្យពួកគេមិនយកកូនច្រើន ។ របស់កុមារ ដែលបណ្តាលមកពីការរៀបការនៅវ័យក្មេងពេក និងការខ្វះចំនេះដឹងរបស់មាតាបិតាដែលធ្វើឲ្យទារកប្រឈមមុខនិង គ្រោះថ្នាក់

# មេរៀនទី៣
# ចីរភាពនៃការប្រើប្រាស់សេវាមូលដ្ឋាន

## សំណួរ

1. តើលទ្ធិភាពប្រើប្រាស់ទឹកស្អាតរបស់ប្រជាជនកម្ពុជា នាំមកនូវផលប្រយោជន៍អ្វីខ្លះ ?
2. តើកង្វះបង្គន់អនាម័យប្រើប្រាស់នៅទីក្រុងឬ នៅជនបទដែលមានកំរិតខ្ពស់ជាង ? ហេតុអ្វី ?
3. តើអ្វីខ្លះជាសក្តានុពលក្នុងការផលិតវារីអគ្គីសនីនៅកម្ពុជា ?
4. តើត្រូវធ្វើដូចម្តេចខ្លះដើម្បីចៀសវាងបាននូវការកាប់ព្រៃឈើសម្រាប់ធ្វើអុស -ធ្យូង ?

## ចម្លើយ

1. លទ្ធិភាពប្រើប្រាស់ទឹកស្អាតរបស់ប្រជាជនកម្ពុជា នាំមកនូវផលប្រយោជន៍ជាច្រើនដូចជា៖
   - ធ្វើឲ្យពួកគាត់អាចជៀសផុតពីជំងឺផ្សេងៗ
   - ធ្វើឲ្យពួកគាត់ចំនិញពេលវេលា និង ថវិកាប្រសិនបើពួកគាត់មិនឈ

2. កង្វះបង្គន់អនាម័យប្រើប្រាស់ នៅជនបទមានកំរិតខ្ពស់ជាង នៅទីប្រជុំជន ពីព្រោះតែះ

- នៅជនបទប្រជាជនមានជីវភាពក្រីក្រជាងនៅជនបទ
- ប្រជាជននៅជនបទមិនបានយល់ដឹងច្រើន ពីផលប្រយោជន៍នៃបង្គន់អនាម័យ
- នៅតំបន់មួយចំនួនពុំមានទឹកសំរាប់ប្រើប្រាស់ទើបពុំអាចប្រើប្រាស់បង្គន់អនាម័យបាន ។

3. សក្តានុពលក្នុងការផលិតវារីអគ្គីសនីនៅកម្ពុជាមានដូចជា ៖

- មានតំបន់ទឹកធ្លាក់ជាច្រើនកន្លែង
- ទឹកជ្រោះដែលមានល្បឿនទឹកហូរខ្លាំង
- មានល្បាក់ខោន
- មានប្រព័ន្ធផ្លូវទឹកជាច្រើនកន្លែង។
- មានបឹង ទន្លេ ដែលមានទឹកពេញមួយឆ្នាំ ។

4. ដើម្បីចៀសវាងបាននូវកាប់ព្រៃឈើសំរាប់ធ្វើអុស- ធ្យូង

- ពង្រឹងច្បាប់អំពីការកាប់ព្រៃខុសច្បាប់
- ដាក់ទោសចំពោះជនណាដែលបានលួចកាប់ព្រៃឈើសម្រាប់ធ្វើ អុស- ធ្យូង ខុសច្បាប់

- អប់រំប្រជាពលរដ្ឋឲ្យយល់ច្បាស់ពីផលប៉ះពាល់ដែលបណ្តាលមកពីការកាប់ព្រៃឈើ
- បង្កើតឧស្ម័នជំនួស អុស ធ្យូងឲ្យបានច្រើននិងមានតម្លៃថោកដើម្បីបំពេញតំរូវការរបស់ប្រជាពលរដ្ឋ
- ធ្វើការណែនាំ លើកទឹកចិត្ត ប្រជាពលរដ្ឋឲ្យប្រើប្រាស់ឧស្ម័នជំនួស អុស-ធ្យូង ។
- បំផុសស្មារតីប្រជាពលរដ្ឋឲ្យចេះជួយថែរក្សាព្រៃឈើ

# ចម្លើយ និង សំណួរបញ្ចប់ជំពូកទី២

ii. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចំលើយត្រូវតែមួយគត់

1. ជំងឺគ្រុនចាញ់អាចកើតមានលើមនុស្ស

☐ក. ចាស់ ☐ខ. ក្មេង

☐គ. ស្ត្រី ☑ ឃ. គ្រប់វ័យ

2. បច្ចុប្បន្នប្រព័ន្ធអប់រំចំណោះទូទៅនៅកម្ពុជា មានរយៈពេល

☐ក. 9ឆ្នាំ ☐ខ. 10ឆ្នាំ

☐គ. 11ឆ្នាំ ☑ឃ. 12ឆ្នាំ

3. ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីការអភិវឌ្ឍអន្តរជាតិ មានអក្សរកាត់ជា

☑ក. USAID ☐ខ.IDH

☐គ. UNTAC ឃ. ☐Fa

iii. ចូលបំពេញឃ្លាខាងក្រោមឲ្យបានត្រឹមត្រូវ

1. គ្រុនចាញ់ជាជំងឺរស់នៅក្នុងកោសិកាឈាមក្រហមបង្ករឡើងដោយមេរោគម្យ៉ាងឈ្មោះ......**អេម៉ាតូសូអ៊ែ**......។

2. អត្ថរភាពមនុស្សពេញវ័យគឺ អ្នកចេះអាន ចេះសរសេរមានអាយុចាប់ពី........**7ឆ្នាំ**...........ឡើងទៅ ។

3. ចំនួនស្ត្រី ស្លាប់ក្នុងមូលហេតុមានគភ៌ក្នុងកំនើតរស់ 1000 នាក់ ហៅថា ....**អត្រាមរណប្រមាណមាតា** ។

## សំណួរគ្រះរិះនិង ចម្លើយ

1. តើជំងឺគ្រុនចាញ់ឆ្លងមកមនុស្សដោយសារអ្វី ? តើជំងឺនេះមានកំរិតខ្ពស់នៅតំបន់ណាខ្លះនៃប្រទេសកម្ពុជា ?

**ចម្លើយ** ជំងឺគ្រុនចាញ់ឆ្លងមកមនុស្សដោយសារ មូសដែកគោលញីខាំ ។ ជំងឺនេះមានកំរិតខ្ពស់នៅតំបន់នៅតំបន់ព្សសាននៃខេត្តរតនគីរី តំបន់អាគ្នេយ៍នៃខេត្តក្រចេះ

តំបន់តាមព្រំប្រទល់រវាងខេត្តព្រះវិហារ និង ខេត្តឧត្តរមានជ័យ ខេត្តបាត់ដំបង ពោធិ៍សាត់ ប៉ៃលិន និង តំបន់ចម្ការកៅស៊ូ ។

2. ហេតុអ្វីបានជាការបរិភោគមិនគ្រប់គ្រាន់ ជាបញ្ហាចោតខ្លាំងចំពោះបណ្តាលប្រទេសកំពុងអភិវឌ្ឍ ?

**ចម្លើយ** បានជាការបរិភោគមិនគ្រប់គ្រាន់ ជាបញ្ហាចោតខ្លាំងចំពោះបណ្តាលប្រទេសកំពុងអភិវឌ្ឍពីព្រោះប្រទេសកំពុងអភិវឌ្ឍ មានប្រជាជនច្រើនលើសលុប ហើយមានកំនើនខ្ពស់រីឯផលិតកម្ម (ពិសេសផលិតកម្មស្បៀង)មានកំណើនយឺត ។

3. តើកត្តាសំខាន់ៗអ្វីខ្លះ ដែលធ្វើឲ្យអត្រាស្លាប់របស់កុមារនៅកម្ពុជាមានកំរិតខ្ពស់នៅឡើយ?

**ចម្លើយ** កត្តាសំខាន់ៗ ដែលធ្វើឲ្យអត្រាស្លាប់របស់កុមារនៅកម្ពុជាមានកំរិតខ្ពស់នៅឡើយមាន ៖

- កង្វះអាហារូបត្ថម្ភ
- កង្វះការថែទាំរបស់មាតាបិតា
- សេវាកម្មសុខភាព
- កង្វះអនាម័យ

▪ ការប្រើប្រាស់ទឹកមិនស្អាត

▪ គ្មានបង្គន់អនាម័យសំរាប់ប្រើ

4. តើវិសមភាពនៃការចូលរៀនមានទំនាក់ទំនងទៅ និង បញ្ហាអ្វី ?

**ចម្លើយ** វិសមភាពនៃការចូលរៀនមានទំនាក់ទំនងទៅ និង បញ្ហា

▪ ជីវភាពក្រីក្រពុំមានលទ្ធិភាពឲ្យកូនទៅរៀនបានវែងឆ្ងាយ

▪ ការបំលាស់លំនៅជាញឹកញាប់របស់គ្រួសារ

▪ ការស្វែងរកការងារធ្វើជាហេតុធ្វើឲ្យកូនចៅមិនបានចូលរៀន

▪ ការរស់នៅតំបន់ដាច់ស្រយាលសាលារៀននៅឆ្ងាយពីផ្ទះកង្វះមធ្យោបាយធ្វើដំណើរ។

5. តើកូនអ្នកនៅទីប្រជុំជន ឬ នៅជនបទដែលមានលទ្ធិភាពបានទទួលការរៀនសូត្របានវែងឆ្ងាយជាង ? ព្រោះអ្វី ?

**ចម្លើយ** កូនអ្នកនៅទីប្រជុំជនមានលទ្ធិភាពបានទទួលការរៀនសូត្របានវែងឆ្ងាយជាងកូននៅជនបទ ពីព្រោះ

- ពួកគេមានជីវភាពធូធារ
- សាលារៀននៅជិតផ្ទះងាយស្រួលក្នុងការធ្វើដំណើរ
- ឪពុកម្តាយរបស់ពួកគេមានការ យល់ដឹងពីសារៈសំខាន់នៃ ការសិក្សា
- ឪពុកម្តាយយកចិត្តទុកដាក់ក្នុងការយកកូនទៅរៀន
- ការរស់នៅក្នុងមជ្ឈដ្ឋានអ្នករៀនសូត្រ
- នៅទីប្រជុំជនសំបូរសាលារៀនរដ្ឋ និងសាលារៀនឯកជន
- ពួកគេមានការជំរុញលើកទឹកចិត្តកូនក្នុងការសិក្សា។

6. តើកំណើនអក្ខរភាពនៃប្រជាជនកម្ពុជាកើតឡើងដោយសារមូលហេតុអ្វី ?

**ចម្លើយ** កំណើនអក្ខរភាពនៃប្រជាជនកម្ពុជា កើតឡើងដោយសារមូល ការអនុវត្តគោលនយោបាយអប់រំរបស់រាជរដ្ឋាភិបាល និង ក្រសួងអប់រំយុវជន និង កីឡាបានសាងសង់ គ្រឹះស្ថានសិក្សាគ្រប់ភូមិសិក្សាទូទាំងប្រទេស និងបានប្រមូលកុមារគ្រប់អាយុឲ្យចូលរៀនការចូលរៀនពុំមានបង់ប្រាក់ទេ ។

7. តើកង្ហះបង្គន់អនាម័យប្រើប្រាស់នៅតាមសាលារៀនផ្ត ល់ផលប៉ះពាល់ចំពោះសិក្សានុសិស្ស ?

**ចម្លើយ** កង្វះបង្គន់អនាម័យប្រើប្រាស់ នៅតាមសាលារៀនផ្តល់ផលប៉ះពាល់ចំពោះសិក្សានុសិស្សគឺ ជះឥទ្ធិពលសំខាន់ដល់សុខភាពនិងលទ្ធផលនៃការរៀនសូត្ររបស់សិស្សានុសិស្ស ។

8. ការប្រើប្រាស់អុសសំរាប់ចំម្អិនអាហារ នាំឲ្យមានផលប៉ះពាល់ដូចម្តេចខ្លះចំពោះបរិស្ថាន និង សុខភាពរបស់មនុស្ស ? ការប្រើប្រាស់អុសសំរាប់ចំម្អិនអាហារនាំឲ្យមានផលប៉ះពាល់ចំពោះបរិស្ថាន និង សុខភាពរបស់មនុស្សដូចជា៖

❖ **ផលប៉ះពាល់ចំពោះបរិស្ថាន**

- បាត់បង់ព្រៃឈើ
- ធ្វើឲ្យមានការប្រែប្រួលអាកាសធាតុច
- ភ្លៀងធ្លាក់មិនទៀងទាត់
- ធ្វើឲ្យមានខ្យល់ព្យុះ ទឹកជំនន់ គ្រោះរាំងស្ងួត
- ធ្វើឲ្យមានសំណឹកដី
- បាត់បង់ជំរកសត្វព្រៃ

- បាត់បង់ប្រភពចំនួលថវិកាជាតិ
- បាត់បង់ប្រភពទាក់ទាញទឹកភ្លៀង។

❖ **ផលប៉ះពាល់ចំពោះសុខភាពរបស់មនុស្ស**

- ធ្វើឲ្យមានជំងឺរលាកផ្លូវដង្ហើម ដោយសារផ្សែងកាបូនចេញពីអុស ។

# ជំពូកទី ៣ សេដ្ឋកិច្ចកម្ពុជា

## មេរៀនទី១ សេដ្ឋកិច្ចកម្ពុជា

### សំណួរ

1. តើគេចែកប្រភេទកសិករនៅកម្ពុជាជាប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
2. តើក្នុងកម្ពុជាស្ត្រីមានតួនាទីអ្វីខ្លះ ក្នុងវិស័យកសិកម្ម ?
3. តើនៅកម្ពុជាគេដាំស្រូវអ្វីច្រើនជាងគេ ? ព្រោះអ្វី ?
4. តើដំណាំកៅស៊ូផ្តល់សារៈសំខាន់អ្វីខ្លះ ដល់សេដ្ឋកិច្ច បរិស្ថាន និង សង្គម ?
5. ការចិញ្ចឹមសត្វនៅកម្ពុជាមានភាពជឿនលឿនហើយ ឬនៅ ? ហេតុអ្វី ?
6. ចូររៀបរាប់អំពីមូលហេតុ ដែលនាំឲ្យបរិមាណត្រីចុះថយ ?
7. តើព្រៃឈើមានសារៈប្រយោជន៍អ្វីខ្លះ ? កន្លងមកនេះ តើព្រៃឈើនៅកម្ពុជាមានលក្ខណៈដូចម្តេច ?តើរដ្ឋាភិបាលមានគោលការណ៍យ៉ាងណាខ្លះក្នុងការការពារព្រៃឈើ?

8. ចូលរៀបរាប់អំពីទំនាក់ទំនងរវាងការដាំដុះ អាជីវកម្ម ព្រៃឈើ និង នេសាទ។

## ចម្លើយ

1. គេចែកប្រភេទកសិករនៅកម្ពុជាជាប្រភេទធំៗដូចជា ៖

- កសិករផលិតស្រូវ ឬ អ្នកស្រែ
- កសិករនៅតំបន់ដីខ្ពស់
- កសិករធ្វើចំការ ឬ កសិករមិនដាំស្រូវ

2. តួនាទីស្ត្រីនៅកម្ពុជាក្នុងវិស័យកសិកម្មដើរតួសំខាន់ណាស់ បន្ថែមពីលើការងារផ្ទះសំបែង (ដាំបាយ បុកស្រូវ កិនស្រូវ ដងទឹក រកអុស និង ថែទាំកូនចៅ) ។ ស្ត្រីត្រូវដាំដំណាំ ប្រមូលផល មើលថែទាំសត្វពាហនៈ និង ត្រូវ ទៅលក់ផលិតផលនៅឯផ្សារទៀតផង ។

3. នៅកម្ពុជាគេដាំស្រូវវស្សាច្រើនជាងគេ ពីព្រោះវាងាយស្រួលដាំ ចំណាយដើមតិច ព្រោះយើងមិនចាំបាច់បូមទឹកដាក់ដូចស្រូវប្រាំង មានរយៈពេលខ្លី ទទួលផលបានច្រើន ។

1. ដំណាំកៅស៊ូផ្តល់សារៈសំខាន់ ដល់សេដ្ឋកិច្ចបរិស្ថាន និង សង្គម ដូចជា ៖

វាបានរួមចំនែកយ៉ាងសកម្មក្នុងការផ្តល់ប្រាក់ចំណូល ដល់ខៀនសេដ្ឋកិច្ចជាតិ និង សង្គមគ្រួសារ បង្កើន ការងារនៅមូលដ្ឋានជនបទ និងទប់ស្កាត់ការធ្វើចំណាក ស្រុក វាថែមទាំបានរួមចំណែកការពារបរិស្ថាន ទប់ទល់ នឹង ភាពក្តៅខ្លាំងនៃអាកាសធាតុ ការហូរច្រោះដីភក់និង បង្កើតជាតម្របបៃតង ជំនួសព្រៃឈើដែលវិចវិល និង ផ្តល់ឈើសម្រាប់ ប្រើប្រាស់និងធ្វើអុសដុត ដែលអាច កាត់បន្ថយការកាប់ព្រៃឈើបាន ។

5. ការចិញ្ចឹមសត្វនៅកម្ពុជាពុំទាន់មានភាពជឿនលឿន នៅឡើយទេ ពីព្រោះការចិញ្ចឹមសត្វមានលក្ខណៈតូច តាចនៅតែក្នុងរង្វង់គ្រួសារ និងខ្វះបច្ចេកទេស ។ ការ ចិញ្ចឹមសត្វមិនបម្រើ ឧស្សាហកម្ម ឬ ជំនួញទេ គឺ បម្រើតែការងារកសិកម្មប៉ុនោះ ជាពិសេសសម្រាប់ធ្វើ ជាកម្លាំងអូសទាញ ។

6. មូលហេតុ ដែលនាំឲ្យបរិមាណត្រីចុះថយមានដូចជា៖
   - ការកាប់បំផ្លាញព្រៃលិចទឹកស្ទើរអស់
   - កណើនមមោកនៅបាត បឹង ទន្លេ ស្ទឹង
   - ការប្រែប្រួលអាកាសធាតុ

- ការប្រើប្រាស់ថ្នាំ និង ជីគីមីក្នុងកសិកម្ម
- បទល្មើសក្នុងការនេសាទនិង ការនេសាទដោយប្រើឧបករណ៍ទំនើប ។

7. សារៈប្រយោជន៍របស់ព្រៃឈើមានដូចជា៖
   - ជាជំរករបស់សត្វព្រៃ និង សត្វមច្ឆាគ្រប់ប្រភេទ
   - ផ្តល់ឈើសំរាប់ធ្វើ សំណង់ ផ្ទះ តុ ទូ ទូក គ្រឿងសង្ហារឹមគ្រប់ប្រភេទនិង ស្លឹកវាសំរាប់ប្រក់ផ្ទះ
   - ជួយរក្សាលំនឹងអាកាសអាធាតុ (ភ្លៀងធ្លាក់ទៀងទាត់)
   - ផ្តល់ខ្យល់អាកាសបរិសុទ្ធ
   - ជួយទប់ទល់ខ្យល់ព្យុះ ទឹកជំនន់
   - ជួយការពារការហូរច្រោះដី (ដីបាក់)
   - ធ្វើឲ្យដីមានជីវជាតិ
   - ជួយទាក់ទាយទឹកភ្លៀង
   - ជួយស្រូបយកឧស្ម័នកាបូនិច និង បញ្ចេញឧស្ម័នអុកស៊ីសែនដល់មនុស្ស ។

កន្លងមកនេះព្រៃឈើនៅកម្ពុជាមានការបាត់បង់ជាបន្តបន្ទាប់គួរឲ្យព្រួយបារម្ភពីមួយឆ្នាំទៅមួយឆ្នាំព្រៃឈើគឺ

មានការថយចុះជាលំដាប់បើគិតតាំងពីឆ្នាំ 1900ផ្ទៃដីព្រៃឈើមាន 75% ប៉ុន្តែនៅបច្ចុប្បន្នព្រៃឈើនៅតិចជាង 40%និងបន្តចុះថយជាលំដាប់ទៀត ។

គោលការណ៍របស់រាជរដ្ឋាភិបាលក្នុងការការពារព្រៃឈើមានដូចជា ៖

- បង្កើនផ្ទៃដីគំរូព្រៃឈើឈានឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍អន្តរជាតិនានាដើម្បីគ្រប់គ្រងព្រៃឈើឲ្យបានល្អ
- បង្កើនតំបន់ការពារធម្មជាតិ (ឧទ្យានជាតិ)
- បង្កើនសហាគមព្រៃឈើ
- ការបោះបង្គោលព្រំដែនព្រៃឈើ
- ការស្រាវជ្រាវនិង អភិរក្សសត្វព្រៃ
- ការដាំដើមឈើឡើងវិញ ។

8. ទំនាក់ទំនងរវាងការដាំដុះ អាជីវកម្មព្រៃឈើនិងនេសាទដើម្បីបំពេញតំរូវការក្នុងផលិតកម្ម និង តំរូវការផ្សេងៗទៀត មនុស្សនាំគ្នាកាប់ព្រៃឈើដែលជាហេតុធ្វើឲ្យមានការប្រែប្រួលអាកាសធាតុ ប៉ះពាល់ដល់ជីវិតមនុស្ស សត្វ និង រុក្ខជាតិ ។ អតិផរណានៃប្រព័ន្ធផលិត

កម្មនាំឲ្យមានកំនើនការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងជីគីមី។ ថ្នាំសម្លាប់សត្វល្អិតនិង ជីគីមីទាំងនោះហូរទៅផ្តុំគ្នានៅទន្លេនិង បឹង ហើយបំផ្លាញជីវិត និង ពូជមច្ឆាជាតិ ។

## មេរៀនទី ២ ឧស្សាហកម្មកម្ពុជា

### សំណួរ

1. ហេតុអ្វីបានជាផ្នែកឯកជនជាកម្លាំងដ៏សំខាន់សម្រាប់ការវិនិយោគនិង កំណើនក្នុងប្រទេស ?
2. ហេតុអ្វីបានជារដ្ឋាភិបាលលើកស្ទួយសហគ្រាសធុនតូចនិង សប្បកម្ម ?
3. តើឧស្សាហកម្មអ្វីដែលំ មានតួនាទីនាំមុខគេក្នុងកំណើនសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន ? តើឧស្សាហកម្មនេះមានភាព រឹងមាំដែរ ឬទេ ? ហេតុអ្វី ?
4. តើការផ្គត់ផ្គង់ទឹកស្អាតមាន សារៈប្រយោជន៍យ៉ាងណាខ្លះចំពោះប្រជាជន ?
5. តើការផ្គត់ផ្គង់អគ្គិសនីមាន អត្ថប្រយោជន៍យ៉ាងណាខ្លះចំពោះសេដ្ឋកិច្ចជាតិ និង សង្គម ?
6. តើអាជីកម្មរ៉ែ នៅកម្ពុជាមាន សកម្មភាពខ្លាំងក្លាហើយ ឬនៅ ? ព្រោះអ្វី ?

7. តើឧស្សាហកម្មមានតួនាទី ចំពោះសេដ្ឋកិច្ចជាតិយ៉ាងណាខ្លះ ?

8. ចូលរៀបរាប់ពីការត្រួតពិនិត្យ គុណភាពផលិតផលឧស្សាហកម្ម ។

## ចម្លើយ

1. បានជាផ្នែកឯកជនជាកម្លាំងដ៏សំខាន់ សម្រាប់ការវិនិយោគនិង កំណើនក្នុងប្រទេស ពីព្រោះបើការណាផ្នែកឯកជនមានកំណើនរឹងមាំ វាអាចបំពេញបន្ថែមវិនិយោគយោគសាធារណៈក្នុងវិស័យសង្គមកិច្ច ដោយស្រូបយកកម្លាំងពលកម្មធ្វើការងារកាន់តែកើនឡើង និង បង្កើនជំនាញផ្សេងៗជាច្រើន ។

2. បានជារដ្ឋាភិបាលលើកស្ទួយសហគ្រាស ធុនតូច និងសប្បកម្ម ពីព្រោះវិស័យនេះបានផ្តល់ការងារដល់កម្មករប្រមាណ 350 000 នាក់ ដែលភាគច្រើនជាស្ត្រីវ័យក្មេងបម្រើការងារក្នុងរោងចក្រកាត់ដេរចំនួន 422 ឆ្នាំ 2009 ។

3. ឧស្សាហកម្មដែល មានតួនាទីនាំមុខគេក្នុងកំណើនសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្នគឺ ឧស្សាហកម្មកាត់ដេរ ។

ឧស្សាហកម្មនេះមិនទាន់មានភាពរឹងមាំទេ ។ ពីព្រោះ តម្រូវការទីផ្សារមុខទំនិញផ្នែកនេះបានថយចុះរួមផ្សំ និង ការប្រកួតប្រជែងទីផ្សារដូចគ្នានៃបណ្តាប្រទេសជិតខាង និង ថ្លៃដឹកជញ្ជូនកើនខ្ពស់ជាងមុនដោយសារមានការ កើនឡើងនៃតំលៃប្រេង ។

4. ការផ្គត់ផ្គង់ទឹកស្អាត មានសារៈប្រយោជន៍ណាស់ ចំពោះប្រជាជនវាធ្វើឲ្យពួកគេមានសុខភាពល្អនិងមាន ជីវភាពធូរធារ ជាពិសេសងាយស្រួលក្នុងការប្រើប្រាស់

5. ការផ្គត់ផ្គង់អគ្គិសនីមានអត្ថប្រយោជន៍ចំពោះសេដ្ឋកិច្ច ជាតិនិង សង្គមវិស័យឧស្សាហកម្មអាចជឿនលឿនទៅ បានអាស្រ័យទៅលើ ការផ្គត់ផ្គង់ថាមពលអគ្គិសនីជា សំខាន់កាលបើថាមពលអគ្គិសនីកាន់តែថោកធ្វើឲ្យ ឧស្សាហកម្មចំណាយតិច ចំណេញបានច្រើន ។ ចំណែក តម្លៃលក់នៅទីផ្សារក៏ថោក ធ្វើឲ្យសេដ្ឋកិច្ច ប្រទេសមានភាពរីកចំរើន ។

6. អាជីកម្មរ៉ែនៅកម្ពុជា ពុំទាន់មានសកម្មភាពខ្លាំងក្លានៅ ឡើយទេ ។ ពីព្រោះ

- កង្វះខាតធនធានមនុស្ស

- ពិសេសកង្វះខាតមន្ត្រីសម្រាប់ប្រតិបត្តិការនៅទូទាំងប្រទេស
- ពុំទាន់មានមហាវិទ្យាល័យ ធ្វើការបណ្តុះបណ្តាលជំនាញផ្នែកភូគព្ភសាស្ត្រ -រ៉ែនៅឡើយ ។

7. ឧស្សាហកម្មមានតួនាទីចំពោះសេដ្ឋកិច្ចជាតិ វាបានរួមចំណែកបាន 23,8 នៃផលិតផលក្នុងស្រុកសរុប និងបានបង្កើតការងារដល់ប្រជាពលរដ្ឋបាន ។

8. រៀបរាប់ពីការត្រួតពិនិត្យ គុណភាពផលិតផលឧស្សាហកម្មមានដូចជា ៖
- ពិនិត្យណែនាំសុវតិភាពប្រើប្រាស់ ឡចំហាយ ម៉ាស៊ីនភ្លើង ម៉ាស៊ីនបូមខ្យល់ និង ឧបករណ៍យោង
- ចុះពិនិត្យស្ថានភាពបរិស្ថាន
- ផ្តល់មតិណែនាំកែលម្អ ទៅលើការបង្ហូរកាកសំណល់រាវ និងកខ្វក់ដោយឲ្យតម្លើងប្រព័ន្ធសម្អាតឬ សម្លាប់មេរោគរួចបង្ហូរចូលទៅក្នុងទន្លេ ឬ បឹង
- ចំពោះរោងចក្រដែលមានក្លិនត្រូវតម្រូវឲ្យមានវិធានការកែលម្អឡើងវិញ ។

# មេរៀនទី៣ គមនាគមន៍កម្ពុជា

## សំណួរ

1. តើប្រទេសកម្ពុជាមានផ្លូវគមនាគមន៍ប៉ុន្មានប្រភេទ ?អ្វីខ្លះ ?
2. តើផ្លូវគោកមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
3. តើប្រទេសកម្ពុជាមានផ្លូវថ្នល់សរុបប្រវែងប៉ុន្មាន ? ក្នុងនោះមានផ្លូវអ្វីខ្លះ ?
4. តើផ្លូវជាតិណាដែលវែងជាងគេ ? កាត់ខេត្តណាខ្លះ ?
5. ហេតុអ្វី បានជាគេចាត់ទុកគ្រោះថ្នាក់ចរាចរណ៍ជាគ្រោះមហន្តរាយដ៏ធំបន្ទាប់ពីជំងឺអេដស៍ ?
6. តើបច្ចុប្បន្នចរាចរណ៍តាមផ្លូវដែកមានសកម្មភាពខ្លាំងក្លាហើយឬ នៅ ? ព្រោះអ្វី ?
7. តើផ្នែកមួយណា ដែលមានសកម្មភាពប្រសើរជាងរវាងសកម្មភាពនាវាចរណ៍តាមប្រព័ន្ធទន្លេមេគង្គ និងកំពង់ផែសមុទ្រ ? ព្រោះអ្វី ?
8. តើអាកាសយានដ្ឋានសំខាន់ៗរបស់ប្រទេសកម្ពុជាស្ថិតនៅឯណាខ្លះ ? តើគម្រោងកសាងអាកាសយាន

ដ្ឋានអន្តរជាតិថ្មីៗ មាននៅខេត្តណាខ្លះ ? 1ហ្វូត (foot) = 30.48cm 40ហ្វីត (feet) = 30.48 × 40 = 12.192 m

## ចម្លើយ

1. ប្រទេសកម្ពុជាមានផ្លូវគមនាគមន៍ បីប្រភេទ ។ មានផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ។
2. ផ្លូវគោកមាន ពីរប្រភេទ ។ មានផ្លូវថ្នល់ និង ផ្លូវដែក ។
3. ប្រទេសកម្ពុជាមានផ្លូវថ្នល់សរុបប្រវែង 39 618 km ។ ក្នុងនោះមាន
   - ផ្លូវជាតិលេខមួយប្រវែង 2 119 km
   - ផ្លូវជាតិលេខពីរប្រវែង 3 086 km
   - ផ្លូវខេត្តប្រវែង 6 413 km
   - ផ្លូវជនបទ(ផ្លូវលំ)ប្រវែង 28 000 km ។
4. ផ្លូវជាតិណាដែលវែងជាងគេគឺ ផ្លូវជាតិលេខ 5 ពីភ្នំពេញ ទៅអូរជ្រៅ (ព្រំប្រទល់ថៃ) ។ វាកាត់តាម ខេត្តកំពង់ឆ្នាំងពោធិ៍សាត់ បាត់ដំបង និង បន្ទាយមានជ័យ មានប្រវែង408 km ។

5. បានជាគេចាត់ទុកគ្រោះថ្នាក់ចរាចរណ៍ជាគ្រោះមហន្តរាយដ៏ធំបន្ទាប់ពីជំងឺអេសដ៍ ពីព្រោះពីមួយថ្ងៃទៅមួយថ្ងៃមានមនុស្សជាច្រើនបានស្លាប់ដោយសារ គ្រោះថ្នាក់ចរាចរណ៍ ដែលជាគ្រោះថ្នាក់មួយដ៏សាហាវបន្ទាប់ពីជំងឺអេដស៍ ។

6. បច្ចុប្បន្នចរាចរណ៍តាមផ្លូវដែកមិនទាន់មានសកម្មភាពខ្លាំងក្លានៅឡើយទេ ។ ដោយសារ ភាពទ្រុឌទ្រោមដោយសង្គ្រាម អស្ថេភាពផ្នែកសន្តិសុខ នយោបាយ និងការរីកចម្រើនខ្ពស់ផ្នែកផ្លូវថ្នល់ ។

7. សកម្មភាពនាវាចរណ៍តាមប្រពន្ធទន្លេមេគ្គ និង កំពង់ផែ សមុទ្រផ្នែកដែលមានសកម្មភាពប្រសើរជាងគេគឺកំពង់ផែសមុទ្រ ។ ពីព្រោះវាជាកំពង់ផែអាចឲ្យនាវាសមុទ្រធំៗ ចូលចតបានគ្រប់រដូវ ជាផែសម្រាប់បំរើសេវាកម្មរុករកប្រេងនៅតាមសមុទ្រនិង ជាផែសម្រាប់ប្រភេទទំនិញមិនវេចខ្ចប់ សម្រាប់បូមគ្រាប់ធញ្ញជាតិជាពិសេសកំពង់ផែរ៉ាម ដែលប្រើប្រាស់សំរាប់ជាមូលដ្ឋាននាវាចរណ៍ខេមរភូមិន្ទ ។

8. អាកាសយានដ្ឋានសំខាន់ៗ របស់ប្រទេសកម្ពុជាស្ថិតនៅទីក្រុងភ្នំពេញ(ពោធិ៍ចិនតុង)សៀមរាប និង ខេត្តព្រះសីហនុ។គម្រោងកសាងអាកាសយានដ្ឋាន អន្តរជាតិថ្មីៗនៅ ខេត្តសៀមរាប ខេត្តកំពង់ឆ្នាំង និងស្ថិតនៅឃុំប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ។

# មេរៀនទី ៤ ពាណិជ្ជកម្មកម្ពុជា

## សំណួរ

1. តើកម្ពុជា បានចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃ ខែ ឆ្នាំណា ? តើការបានចូលនេះមានផលប្រយោជន៍យ៉ាងណាខ្លះ ?
2. តើក្រុមហ៊ុនណាខ្លះ ដែលផ្ដល់ផលិតផលសម្រាប់ការនាំចេញបានច្រើនជាងគេ ?
3. ចូររៀបរាប់អំពីទីផ្សារសំខាន់ៗរបស់កម្ពុជា ។ តើទីផ្សារណាដែលមានបរិមាណទឹកប្រាក់ច្រើនជាងគេ ? ហេតុអ្វី?
4. តើប្រភេទទំនិញសំខាន់ៗអ្វីខ្លះ នៅក្នុងការនាំចូលរបស់កម្ពុជា ?
5. ហេតុអ្វីបានជាការនាំចូលមានកម្រិតខ្ពស់ជាងការនាំចេញ ? តើត្រូវធ្វើដូចម្ដេច ដើម្បីកាត់បន្ថយកម្រិតនាំចូលឲ្យបានជាអតិបរមា ?
6. តើជញ្ជីងពាណិជ្ជកម្មនៅកម្ពុជា មានលក្ខណៈដូចម្ដេច ? ហេតុអ្វី ?

7. តើការត្រួតទំនិញនៅតាមទីផ្សា គម្រង់ឆ្ពោះទៅរកគោលដៅសំខាន់ៗអ្វីខ្លះ ?

8. តើការរៀបចំពិព័រណ៍ក្នុង និង ក្រៅប្រទេស មានសារៈប្រយោជន៍យ៉ាងណាខ្លះចំពោះវិស័យកសិកម្ម ?

9. តើកិច្ចការសំខាន់ៗអ្វីខ្លះ ដែលត្រូវអនុវត្តដើម្បីជំរុញវិស័យពាណិជ្ជកម្មឲ្យមានសំទុះទៅមុខ ?

## ចម្លើយ

1. កម្ពុជាបានចូលជាសមាជិកនៃ អង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃ 28-30 ខែកញ្ញា ឆ្នាំ 2009។សារៈប្រយោជន៍នៃការចូលជាសមាជិកមានដូចជា៖

- ធ្វើឲ្យមុខមាត់កម្ពុជាកាន់តែត្រូវបានលើកតម្កើងលើឆាកអន្តរជាតិ
- កម្ពុជាអាចបោះជំហានទៅកាន់ទីផ្សារពិភពលោកយ៉ាងស្វាហាប់
- បង្កើនទំនាក់ទំនងទ្វេភាគ ពហុភាគីដ៏ទូលំទូលាយជាមួយប្រទេសនានា
- ផ្តល់ឱកាសមាសសម្រាប់ការ ធ្វើពាណិជ្ជកម្មនិងវិនិយោគលើគ្រប់វិស័យនៅកម្ពុជា ។

2. ក្រុមហ៊ុនដែលផ្តល់ផលិតផល សម្រាប់ការនាំចេញបានច្រើនជាងគេមាន ក្រុមហ៊ុនកាត់ដេរសម្លៀកបំពាក់ និងក្រុមហ៊ុនស្បែកជើង ។

3. ទីផ្សារសំខាន់ៗមាន ទ្វីបអាមេរិកទាំងមូល ទ្វីបអឺរ៉ុប អាហ្វ្រិក អាស៊ី អូសេអានី និង សាធារណៈរដ្ឋសង្គមនិយមវៀតណាម ។ ទីផ្សារដែលមានបរិមាណទឹកប្រាក់ច្រើនជាងគេគឺ សហរដ្ឋអាមេរិក ។ដោយសារកម្ពុជាទទួលបានគោលការណ៍ អនុគ្រោះពន្ធកម្រិតសូន្យលើមុនទំនិញចំនួន 177មុខ ពីសហរដ្ឋអាមេរិក ។

4. ប្រភេទទំនិញសំខាន់ៗ នៅក្នុងការនាំចូលរបស់កម្ពុជាមាន ម្ហូបអាហារ ភេសជ្ជៈ សារធាតុគីមី ប្រេងឥន្ធនៈ ឱសថ បរិក្ខារពេទ្យ គ្រឿងសំអាង វត្ថុធាតុដើមសម្រាប់ឧស្សាហ៍កម្មកាត់ដេរ សម្ភារៈសំណង់ និងយានជំនិះគ្រប់ប្រភេទ ។

5. បានជាការនាំចូល មានកម្រិតខ្ពស់ជាងការនាំចេញដោយសារប្រទេសយើង នៅមិនទាន់មានភាពរីចម្រើនខាងផ្នែកឧស្សាហកម្ម និងកសិកម្មមិនអាចបំពេញតំរូវការចាំបាច់របស់ប្រជាជនកម្ពុជា ជាមួយនិងភាពរីកចំរើ

នកើនឡើងផ្នែកជីវភាពរស់នៅនិង តំរូវការប្រើប្រាស់ ដើម្បីកាត់បន្ថយការនាំចូល ដំបូងយើងត្រូវ ៖

- បង្កើនផលិតផលក្នុងស្រុករបស់យើង ជាពិសេសផលិតផលកសិកម្ម និង ឧស្សាហកម្ម
- តំឡើងពន្ធក្នុងការនាំចូល ប៉ុន្តែតំលើងពន្ធក្នុងការនាំចេញ
- កាត់បន្ថយកំនើនប្រជាជន ។
- បំផុសស្មារតីប្រជាជន ឲ្យធ្វើការប្រើប្រាស់ផលិតផលក្នុងស្រុក ។

6. ជញ្ជីងពាណិជ្ជកម្មនៅកម្ពុជា មានលក្ខណៈជញ្ជីងពាណិជ្ជកម្មនៅកម្ពុជានៅមានឱនភាពនៅឡើយ ។ ពីព្រោះការនាំចូលគ្របដណ្តប់លើការនាំចេញ ។
7. ការត្រួតទំនិញនៅតាមទីផ្សារ តម្រង់ឆ្ពោះទៅរកគោលដៅសំខាន់ៗដូចជា ៖
   - ការត្រួតពិនិត្យលើ គ្រោះថ្នាក់ផ្នែកគីមី
   - ការត្រួតពិនិត្យលើ ផ្នែកអនាម័យ
   - ការត្រួតពិនិត្យលើ ការក្លែងបន្លំ

- ការត្រួតពិនិត្យលើ ប្រេងឥន្ទនៈ និងផលិតផលគីមីកសិកម្ម ។

8. ការរៀបចំពិព័រណ៍ក្នុង និង ក្រៅប្រទេសមានសារៈប្រយោជន៍ខ្លាំងណាស់ចំពោះវិស័យកសិកម្មដូចជា ៖
- លើកដំកើនកម្ពស់កិត្យានុភាពជាតិ
- ធ្វើឲ្យសាធារណជនទទួលផលិតផលប្រើប្រាស់ក្នុងស្រុក
- ជំរុញឲ្យមានការកែលម្អគុណភាព និងម៉ូតផលិតផល
- រុញច្រានផលិតផលខ្មែរជ្រៀតចូលទៅក្នុងទីផ្សារបរទេស ។

9. កិច្ចការសំខាន់ៗ ដែលត្រូវអនុវត្តដើម្បីជុំរុញវិស័យពាណិជ្ជកម្មឲ្យមានសំទុះទៅមុខមាន ៖
- ការរៀបចំពិព័រណ៍ក្នុងនិង ក្រៅប្រទេស
- ការតាមដានទីផ្សារនិង ស្ថេភាពតម្លៃ
- ការងារអភិវឌ្ឍផលិតផល និងស្វែងរកទីផ្សារជូនពាណិជ្ជករនិង កសិករ
- ការងារអវឌ្ឍពាណិជ្ជកម្ម និងសកម្មភាពពង្រឹងដៃគូពាណិជ្ជកម្ម ។

---

## មេរៀនទី ៥ ទេសចរណ៍កម្ពុជា

### សំណួរ

1. ហេតុអ្វីបានជាគេថាវិស័យទេសចរណ៍ ជាឧស្សាហកម្មគ្មានផ្សែង ?
2. ចូលរាប់ពីទីផ្សារទេសចរណ៍ទាំង 10 របស់កម្ពុជា ។ តើទេសចរណ៍ប្រទេសណាដែលមកកម្ពុជាមានកំណើនខ្ពស់ជាងគេ ? ហេតុអ្វី ?
3. តើការងារអ្វី ដែលប្រទេសកម្ពុជាទទួលបានពីវិស័យទេសចរណ៍ ?
4. តើផលិតកម្មក្នុងវិស័យកសិកម្ម អាចបម្រើឲ្យផលប្រយោជន៍វិស័យទេសចរណ៍ដែរ ឬទេ ? ហេតុអ្វី ?
5. តើភោគទ្រព្យទេសចរណ៍នៅកម្ពុជាមានអ្វីខ្លះ ? ចូររៀបរាប់ ?
6. ចូលរៀបរាប់ពីផលិតផលទេសចរណ៍ថ្មី ?
7. ហេតុអ្វីបានជាប្រជាជនកម្ពុជានិយមធ្វើ ទេសចរណ៍ក្នុងស្រុក ?
8. តើអ្វីខ្លះ ជាផលអវិជ្ជមានដែលបណ្តាលមកពីវិស័យទេសចរណ៍ ?

## ចម្លើយ

1.បានជាគេថាវិស័យទេសចរណ៍ ជាឧស្សាហកម្ម គ្មានផ្សែង ពីព្រោះ៖

- វាបានរួមចំណែកកសាងសេដ្ឋកិច្ចសង្គម
- បង្កើនឱកាសការងារ
- បង្កើនប្រាក់ចំណូល
- លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន
- កាត់បន្ថយភាពក្រីក្រ
- ប្រាក់ចំណូលដែលបានមកត្រូវបញ្ចូលក្នុងចរន្តសេដ្ឋកិច្ចជាតិភ្លាមៗ
- រួមចំណែកជំរុញផលិតផលក្នុងស្រុក
- ធ្វើឲ្យមានលំនឹងជញ្ជីងពាណិជ្ជកម្ម ។

2. រាប់ពីទីផ្សារទេសចរណ៍ទាំង 10 របស់កម្ពុជាមាន កូរ៉េ វៀតណាម ជប៉ុន អាមេរិក ចិន ថៃ អង់គ្លេស បារាំង អូស្ត្រាលី តៃវ៉ាន់ ។ទេសចរណ៍ប្រទេសដែលមកកម្ពុជាមានកំណើនខ្ពស់ជាងគេគឺ កូរ៉េ ដោយសារ ពួកគេចង់មកផ្សព្វផ្សាយសាសនា មកទេសចរណ៍ដើម្បីមើលស្ថានភាពប្រទេសយើងដើម្បីមកធ្វើជំនួញ និងបង្កើត

រោងចក្រមកទេសចរណ៍ដើម្បី រកមើលស្ត្រីខ្មែរធ្វើជាប្រពន្ធ ។

3. ការងារដែលប្រទេសកម្ពុជាបានពីវិស័យទេសចរណ៍មាន

- សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះភ្ញៀវ
- ការដឹកជញ្ជូន ( រថយន្ត ម៉ូតូ កង់ រទេះសេះ រទេសគោ ដំរី )
- ការផ្គត់ផ្គង់ចំណីអាហារ (ភោជនីយដ្ឋាន រមណីយដ្ឋាន បាយកាហ្វេ ហាងលក់បាយ )
- មគ្គុទេសទេសចរណ៍
- មហាវិទ្យាល័យទេសចរណ៍ឯកជន
- លក់វត្ថុអនុស្សាវរីយ៍

4. ផលិតកម្មក្នុងវិស័យកសិកម្ម អាចបម្រើឲ្យផលប្រយោជន៍វិស័យទេសចរណ៍បាន ។ ដោយសារយន្តការ និងចលនា " ភូមិមួយ ផលិតផលមួយ " ។

5. ភោគទ្រព្យទេសចរណ៍នៅកម្ពុជាមាន ៖

❖ ភោគទ្រព្យទេសចរណ៍ធម្មជាតិមាន ខ្លង់រាប គីរីរម្យ ភ្នំបូកគោ កែប រាម បុទុមសាគរ ភ្នំគូលែននិង វីរជ័យ

ថែមពីនេះទៀតមានដែនជំម្រកសត្វព្រៃចំនួន១០និង តំបន់ការពារធម្មជាតិចំនួន៦កន្លែង ។

❖ ភោគទ្រព្យទេសចរណ៍ប្រវត្តិសាស្ត្រ និងវប្បធម៌ មណ្ឌលអង្គរ មានប្រាសាទអង្គរវត្ត អង្គរធំ និង វត្តភ្នំជីសូរ សារមន្ទីរ ប្រាសាទព្រះវិហារ អង្គរបុរី ប្រាសាទនៅទន្លេបាទី ភ្នំបាសិត ប្រាសាទសំបូរព្រៃគុហ៍ តំបន់ហ្លួងព្រះស្តេចកន ស្តេចបុរាណកំពង់ក្តី ប្រាសាទកោះកេរ្តិ៍ បឹងមាលា ។សារមន្ទីរជាតិ គុកទួលស្លែង និង ជើងឯក តំបន់អន្លង់វែង ។

6.រៀបរាប់ពីផលិតផលទេសចរណ៍ថ្មីមានដូចជា៖
ពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ ពិធីបុណ្យច្រត់ព្រះនង្គ័ល ការរត់ប្រណាំងអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុង ការប្រកួតកីឡាវាយកូនគោល ។

7.បានជាប្រជាជនកម្ពុជា និយមធ្វើទេសចរណ៍ក្នុងស្រុក ដោយសារ ៖

- ការរីកចំរើនផ្នែកមធ្យោបាយដឹកជញ្ជូន
- ហេដ្ឋារចនាសម្ព័ន្ធ ស្ពានថ្នល់
- ការរីកចំរើនខាងជីវភាព

- ការរីកចំរើនផ្នែកកម្សាន្តសប្បាយ
- កំរិតល្អូតលាស់ខាងការយល់ដឹងរបស់ប្រជាជនអំពីសុខុមាលភាពក្នុងការរស់នៅ ។

# មេរៀនទី ៦ បញ្ហាមីននៅកម្ពុជា

## សំណួរ

1. តើមីនជាអ្វី ? ប្រើសំរាប់ធ្វើអ្វី ?
2. តើខេត្តណាខ្លះដែលសំបូរមីន ? ហេតុអ្វី ?
3. តើទីកន្លែងណាខ្លះ ដែលត្រូវចៀសវាង មិនត្រូវចូលទៅ ដើម្បីបង្ការគ្រោះថ្នាក់ដោយសារគ្រាប់មីន ?
4. តើមីនមានទំនាក់ទំនងទៅនិង ភាពក្រីក្ររបស់ប្រជាជនយ៉ាងណាខ្លះ ?
5. ហេតុអ្វីបានជាគ្រោះថ្នាក់ដោយសារគ្រាប់មីននិង គ្រាប់មិនទាន់ផ្ទុះមានការថយចុះ ?
6. ចូររៀបរាប់ឈ្មោះអង្គភាព និងអង្គការ បោសសំអាតមីននៅកម្ពុជា ?
7. តើការបោសសំអាតមីនមានគោលបំណងអ្វីខ្លះ ?
8. តើមីនមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?តើគ្រាប់មីនមិនទាន់ផ្ទុះមានប៉ុន្មានប្រភេទ ?

10.តើច្បាប់ហាមប្រើប្រាស់គ្រាប់មីនមានខ្លឹមសារដូចម្តេច ?

## ចម្លើយ

1. មីន ជាគ្រឿងផ្ទុះម៉្យាង ។ សំរាប់យកទៅប្រើប្រាស់នៅក្នុងពេលសង្គ្រាម ដើម្បីកម្ទេចវត្ថុផ្សេង ។
2. ខេត្តដែលសំបូរមីន មាននៅតំបន់៣យ័ព្យ
   - ខេត្តបាត់ដំបង
   - ខេត្តប៉ៃលិន
   - ខេត្តឧត្ដរមានជ័យ
   - ខេត្តសៀមរាប
   - ខេត្តព្រះវិហារ
   - ខេត្តបន្ទាយមានជ័យ ។

   ដោយសារតំបន់ទាំងនេះ ស្ថិតនៅសមរភូមិមានការប្រយុទ្ធគ្នាក្នុងសម័យសង្គ្រាម ជាទីតាំងឈរជើង ឬបន្ទាយចាស់ការពារសន្តិសុខរបស់ទាហាន ។
3. ទីកន្លែងដែលត្រូវចៀសវាង មិនត្រូវចូលទៅដើម្បីបង្ការគ្រោះថ្នាក់ដោយសារគ្រាប់មីនមានដូចជា ៖
   - មិនចូលទៅក្នុងបន្ទាយចាស់
   - មិនចូលក្រោមស្ពានបាក់បែក
   - មិនចូលទៅក្នុងភូមិចាស់ដែលគេបោះបង់ចោល

- មិនចូលក្នុងតំបន់ដែលមានសញ្ញាសម្គាល់មីន
- មិនប៉ះពាល់គ្រាប់មីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះ ។

4. មីនមានទំនាក់ទំនងទៅនិង ភាពក្រីក្ររបស់ប្រជាជនដោយសារ ៖ ប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រពួកគាត់ប្រកបមុខរបរកសិកម្ម ប្រសិនបើផ្ទៃដីនោះវត្តមានគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះវាជាឧបសគ្គមួយដ៏ធំចំពោះផលិតកម្មកសិកម្មរបស់ពួកគាត់ នោះនឹងធ្វើឲ្យពួកគាត់កាន់តែមានជីវភាពក្រីក្រថែមទៀត ។

5. បានជាគ្រោះថ្នាក់ដោយសារគ្រាប់មីន និង គ្រាប់មិនទាន់ផ្ទុះមានការថយចុះពីព្រោះ តែការខិតខំប្រឹងប្រែងនិង កិច្ចសហប្រតិបត្តិការរបស់អ្នកចូលរួមជាច្រើន ក្នុងវិស័យសកម្មភាពមីន ជាពិសេសការលើកម្ពស់ការអប់រំការយល់ដឹងអំពី មីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះដល់ប្រជាពលរដ្ឋតាមសហគមន៍នីមួយៗ ។

6. ឈ្មោះអង្គភាព និងអង្គការ ដែលបានបោសសំអាតមីននៅកម្ពុជា

- កងកំលាំងរក្សាសន្តិសុខអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (អ៊ុនតាក់ UNTAC)

- មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (ស៊ីម៉ាក់ GMAC )
- អង្គការមិនមែនរដ្ឋាភិបាលបោសសំអាតមីន (ម៉ាក់ -MAG)
- អង្គការជំនួយសកម្មភាពកំចាត់មីនជប៉ុន (ជេម៉ាក់-JMAS)
- កងកំលាំងវិស្វកម្មនៃកងយោធពលខេមរភូមិន្ទ ។

7. ការបោសសំអាតមីនមានគោលបំណងដើម្បីការពារប្រជាពលរដ្ឋឲ្យចៀសផុតពីការរងគ្រោះថ្នាក់ដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះ និង ដើម្បីឲ្យមានសុវត្ថិភាពក្នុងការប្រើប្រាស់ដីធ្លីនៅតាមសហគមន៍ជនបទ ។

8. មីនដែលប្រើប្រាស់នៅកម្ពុជាមាន ពីរប្រភេទ គឺមីនប្រឆាំងមនុស្ស និងមីនប្រឆាំងរថក្រោះ ។

9. គ្រាប់មីនមិនទាន់ផ្ទុះមាន៥ប្រភេទគឺគ្រាប់បែកដៃ គ្រាប់កាំភ្លើងត្បាល់ គ្រាប់កាំភ្លើងធ្លោង គ្រាប់រ៉ុកកែត និង គ្រាប់ទំលាក់ពីលើយន្តហោះ ។

10. ច្បាប់ហាមប្រើប្រាស់គ្រាប់មីនមានខ្លឹមសារ

- ជនណាកាន់កាប់ ថែរក្សាទុកដោយចេតនានូវគ្រាប់

មិនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពីមួយខែ ដល់មួយឆ្នាំ និង ពិន័យជាប្រាក់ពីមួយលានរៀលដល់ម្ភៃលានរៀល ។ ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេជាពីរ ។

- ជនណាផលិត ជួញដូរ នាំចូល ឬនាំចេញគ្រាប់មីនគ្រប់ប្រភេទ ត្រូវផ្តន់ន្ទាទោសដាក់ពន្ធនាគារពីប្រាំឆ្នាំដល់ ដប់ឆ្នាំ និង ពិន័យជាប្រាក់ពីដប់លាន ទៅម្ភៃលានរៀល។ ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេជាពីរ ។

## សំណួរបញ្ចប់ជំពូកទី៣

**i. ចូរគូសសញ្ញា✓ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់**

1. នៅកម្ពុជាវិស័យសេដ្ឋកិច្ចជាតិដែលផ្តល់ការងារឲ្យប្រជាជនបានច្រើនជាងគេគឺ

☐ក.កសិកម្ម ☐ខ.ឧស្សាហកម្ម

☑ឃ.ទេសចរ ☐ឃ.គមនាគមន៍

2. ទីផ្សារសំខាន់ក្នុងការនាំចេញរបស់កម្ពុជាដែលមានបរិមាណទឹកប្រាប់ច្រើនជាងគេគឺ

☐ក.កាណាដា

☑ខ.សហគមន៍អឺរ៉ុប

☐គ.សហរដ្ឋអាមេរិក

☐ឃ.វៀតណាម

3. តំបន់អេកូទេសចរណ៍ដែលភ្ញៀវអន្តរជាតិចូលចិត្តទៅកម្សាន្តគឺ

☑ក.សៀមរាម

☐ខ.ភូមិភាគឦសា

☐គ.ឆ្នេរ

☐ឃ. ភ្នំពេញ

## ii. ចូរបំពេញឃ្លាខាងក្រោមឲ្យបានត្រឹមត្រូវ

1. ផ្នែកសំខាន់ៗទាំងបួននៃវិស័យកសិកម្ម រួមមាន ការដាំដុះព្រៃឈើការចិញ្ចឹមសត្វនិង ........ការនេសាទ.....។

2. ខេតដែលមានចម្ងាយផ្លូវវែងជាងគេគិតពីភ្នំពេញទៅ គឺ ខេត្ត......រតនគីរី........។

3.ក្រុមហ៊ុនដែលផ្តល់ផលិតផលនាំចេញបានរូបិយប័ណ្ណច្រើនជាងគេគឺ ក្រុមហ៊ុន........កាត់សំលៀកបំពាក់និងស្បែកជើង.... ។

4.អង្គភាពដែលធ្វើសកម្មភាពបោសសំអាតមីនខ្លាំងក្លាជាងគេនៅកម្ពុជាគឺ ....ស៊ីម៉ាក់..។

### iii. សំនួរ និង ចម្លើយ

1.ហេតុអ្វីបានជា សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកសំខាន់ទៅលើពឹងផ្អែកលើកសិកម្ម ។ បានជាសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកសំខាន់ ទៅលើកសិកម្ម ពីព្រោះ ប្រជាជនជាង 80% ជាកសិករដែលមានជីវភាពពឹងផ្អែកទៅលើវិស័យកសិកម្ម ។

2.រៀបរាបពីមូលហេតុ ដែលនាំឲ្យមានអគ្រោះគ្រោះថ្នាក់ចរាចរណ៍ខ្ពស់នៅកម្ពុជា ? តើគ្រោះថ្នាក់ចរាចរណ៍ផ្តល់ផលប៉ះពាល់យ៉ាងណាខ្លះ ចំពោះសេដ្ឋកិច្ចនិង សង្គម ?មូលហេតុ ដែលនាំឲ្យមានអគ្រោះគ្រោះថ្នាក់ចរាចរណ៍ខ្ពស់នៅកម្ពុជាដោយសារតែ

- ភាពមិនគោរពចរាចរណ៍របស់ប្រជាពលរដ្ឋ
- មិនចេះគោរពគ្នាទៅវិញទៅមកនិងខ្វះការប្រុងប្រយ័ត្ន

- បើកបរនៅពេលស្រវឹងស្រា
- បើកបរក្នុងល្បឿនលឿន ដោយមិនពាក់មួកសុវត្ថិភាព ។

គ្រោះថ្នាក់ចរាចរណ៍ផ្តល់ផលប៉ះពាល់ ចំពោះសេដ្ឋកិច្ចនិង សង្គម យ៉ាងធ្ងន់ធ្ងរដូចជា ៖

- បាត់បង់ធនធានមនុស្ស
- ខាតបង់ពេលវេលាធ្វើការងារ និង ថវិកាសម្រាប់ព្យាបាលខ្លួន ។

3. តើសកម្មភាពសំខាន់ៗអ្វីខ្លះ ដែលជំរុញពាណិជ្ជកម្មឲ្យរីក ចម្រើនបាន ?សកម្មភាពសំខាន់ៗ ដែលជំរុញពាណិជ្ជកម្មឲ្យរីកចម្រើនបានមាន ៖

- ការរៀបចំពិព័រណ៍ក្នុងនិង ក្រៅប្រទេស
- ការតាមដានទីផ្សារនិង ស្ថេភាពតម្លៃ
- ការងារអភិវឌ្ឍផលិតផល និងស្វែងរកទីផ្សារជូនពាណិជ្ជករនិង កសិករ
- ការងារអវឌ្ឍពាណិជ្ជកម្ម និងសកម្មភាពពង្រឹងដៃគូពាណិជ្ជកម្ម ។

4. កត្តាសំខាន់ៗ អ្វីខ្លះដែលជំរុញឲ្យវិស័យទេសចរណ៍រីកចម្រើនបាន ? កត្តាសំខាន់ៗដែលជំរុញឲ្យវិស័យទេសចរណ៍រីកចម្រើនបានមាន ៖ មរតកប្រវត្តិសាស្ត្រ វប្បធម៌ ទេសភាពធម្មជាតិ មានកិច្ចការពារបានត្រឹមត្រូវ និងភាពរក្សានូវសន្តិសុខចំពោះភ្ញៀវទេសចរណ៍ សណ្ដាប់ធ្នាប់ អនាម័យ និង សេវាកម្ម ។

5. ដើម្បីចៀសវាងពីបញ្ហាមីន និងគ្រាប់មិនទាន់ផ្ទុះតើអ្នកជួយអប់រំផ្សព្វផ្សាយ ដល់មិត្តភក្តិគ្រួសារឲ្យគាត់យល់ដឹងពីប្រការអ្វីខ្លះ ? ដើម្បីចៀសវាងពីបញ្ហាមីននិងគ្រាប់មិនទាន់ផ្ទុះ ខ្ញុំនិងជួយអប់រំផ្សព្វផ្សាយ ដល់មិត្តភក្តិគ្រួសារឲ្យគាត់យល់ដឹងពីប្រការ ៖

- ពន្យល់ណែនាំប្រជាពលរដ្ឋឲ្យដឹងពីគ្រោះថ្នាក់ដែលបណ្ដាលមកពីគ្រាប់មីន
- ដាក់ផ្លាកសញ្ញាបង្ហាញពីតំបន់ដែលមានគ្រាប់មីនឲ្យប្រជាជនបានដឹងគ្រោះថ្នាក់
- អប់រំកុំឲ្យប៉ះពាល់គ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ
- ធ្វើការរាយការណ៍ជាបន្ទាន់ជូនប្រធានភូមិ សមត្ថកិច្ច

ឬ អ្នកដោះមីននៅពេលដែលយើងបានប្រទះឃើញ គ្រាប់មីន ។

## iv. លំហាត់ និង ចម្លើយ

1. នៅឆ្នាំ 2008 ផ្នែកកាត់ដេរសម្លៀកបំពាក់ប្រើប្រាស់ ពលករប្រមាណ 4.90% នៃប្រជាជនសកម្ម គឺស្មើនឹង 345 860នាក់ ។ ចូរគណនាចំនួនប្រជាជនសកម្មនៅឆ្នាំ 2008 ។

**ចម្លើយ**

- ចំនួនប្រជាជនសកម្មនៅឆ្នាំ 2008

  ដោយយើងដឹងថា៖ ពលករប្រមាណ 4 90% នៃប្រជាជនសកម្មគឺស្មើនឹង345 860 នាក់

ចំនួនប្រជាជនសកម្ម $= \frac{345860 \times 100}{4.90} = 7058367.3$ នាក់

ដូច្នេះ៖

| ចំនួនប្រជាជនសកម្មនៅឆ្នាំ 2008 ស្មើ 7058367.3 នាក់ |
|---|

2. ស្ពានវែងៗចំនួនបីគឺ ស្ពានកោះកុង ស្ពានព្រែកតាមាស់ និង ស្ពានព្រែកក្ដាមមានប្រវែងសរុប 4424m ។ គេដឹងថា

ស្ពានព្រែព្នៅ 357m និង វែងជាស្ពានព្រែកក្តាម 919m។ ចូរគណនាប្រវែងស្ពាននីមួយៗ ។

**ចម្លើយ**

គណនាប្រវែងស្ពាននីមួយៗ

យើងដឹងថា ៖ ស្ពានសរុបស្មើ 4 424m

ស្ពានកោះកុងវែងជាងស្ពានព្រែកព្នៅ 357m និងវែងជាងស្ពានព្រែកក្តាម 919m

យើងតាង $A$ ប្រវែងស្ពានកោះកុង

$B$ ប្រវែងស្ពានព្រែកព្នៅ

$C$ ប្រវែងស្ពានព្រែកព្រែកក្តាម

យើងបាន

$$A = B + 357 \quad (1)$$

$$A = C + 919 \quad (2)$$

យក(1)ផ្ទឹម(2)យើងបាន

$$B + 357 = C + 919$$

$$\Rightarrow B = C + 919 - 357$$

$$\Rightarrow B = C + 562 \quad (3)$$

យើងមាន $A+B+C=4424$

$$A+C+562+C=4424$$

$$A+2C+=4424$$

$$A+2C=4424-562$$

$$A+2C=$$

$$\Rightarrow A=3862-2C\ (4)$$

យក(4)ជំនួសចូល(2)យើងបាន

$$3862-2C=C+919$$

$$\Rightarrow 3C=3862-919$$

$$\Rightarrow C=\frac{3862-919}{3}=981m$$

យក $C$ ជំនួសចូល(3)និង(4)យើងបាន

$$B=C+562 \qquad (3)$$

$$B=981+562$$

$$B=1543m$$

$$A=3862-2C \quad (4)$$

$$A=3862-(2\times 981)$$

$$A=1900m$$

ដូចនេះ ប្រវែងស្ពានកោះកុង $A=1900m$

ប្រវែងស្ពានព្រែកញ្ញៅ $B=1543m$

ប្រវែងស្ពានព្រែកក្ដាម $C=981m$

# ជំពូកទី ៤ នគរូបនីយកម្មនៅកម្ពុជា

## មេរៀនទី ១ លក្ខណៈប្រវត្តិសាស្ត្រនៃការអភិវឌ្ឍទីក្រុង

### សំណួរ

1. ចូរកំនត់ន័យនៃពាក្យ " នគរូបនីយកម្ម " ។
2. ចូរបង្ហាញថា ដូនតាយើងជំនាន់ដើមមានទេពកោសល្យខ្ពស់លើការងារនគរូបនីយកម្ម ។
3. ហេតុអ្វីបានជានគរូបនីយកម្មនៅកម្ពុជាឈប់ដំណើរការចាប់ពីដំណាច់ទសវត្សរ៍ ឆ្នាំ 1960 មក ?
4. ហេតុអ្វីបានជាគេនិយាយថា នគរូបនីយកម្មសម័យខ្មែរខ្មែរក្រហមមានលក្ខណៈបញ្ច្រាសទិស ?
5. ចូរនិយាយអំពីសារៈសំខាន់ នៃការអនុវត្តគោលនយោបាយបែងចែកដីធ្លីនៅកម្ពុជា ។

### ចម្លើយ

1.កំនត់ន័យនៃពាក្យ " នគរូបនីយកម្ម " គឺជាដំណើររៀបចំដែនដីកិច្ចអភិវឌ្ឍទីក្រុងនិង ខេត្តនានាពិសេស

ការរៀបចំប្លង់សម្រាប់ប្រើប្រាស់ដីធ្លី ឲ្យបានសមស្រប ទៅតាមភាពរីកចម្រើនសង្គមសេដ្ឋកិច្ចជាតិ ។

2. បង្ហាញពី ដូនតាយើងជំនាន់ដើមមានទេពកោសល្យខ្ពស់លើការងារនគរូបនីយកម្ម លោកចេះគ្រប់គ្រង និងរៀបចំដែនដី បង្កើតឲ្យមានភូមិ ឃុំ ស្រុក ខេត្ត ទីក្រុងរាជធានីគមនាគមន៍កំពង់ផែ ដីស្រែចម្ការ សិប្បកម្មនិងពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស ។

3. បានជានគរូបនីយកម្មនៅកម្ពុជាឈប់ដំណើរការចាប់ពីដំណាច់ទសវត្សរ៍ឆ្នាំ ១៩៦០មក ពីព្រោះនៅពេលនោះកម្ពុជាបានជាប់ពាក់ពន្ធ័បន្តិម្តងៗ ទៅក្នុងសង្គ្រាមវៀតណាម ។

4. បានជាគេនិយាយថា នគរូបនីយកម្មសម័យខ្មែរក្រហមមានលក្ខណៈបញ្ច្រាសទិស ពីព្រោះពួកមេដឹកបានជំលៀសប្រជាជនពីទីក្រុងភ្នំពេញ 2លាននាក់ដោយបង្ខំឲ្យចាកចេញពីលំនៅឋានក្នុងរយៈពេល ៤៨ម៉ោងនិយាយអំពីសារៈសំខាន់ នៃការអនុវត្តគោលនយោបាយបែងចែកដីធ្លីនៅកម្ពុជា ៖

- នាំរកការកាត់បន្ថយភាពក្រីក្រដោយផ្ទាល់

- រួមចំណែកក្នុងការកាត់បន្ថយទិវាទដីធ្លី
- អាចឲ្យគេប្រើប្រាស់ដីនិងកម្លាំងពលកម្មដែលនៅទំនេរប្រកបដោយប្រសិទ្ធភាព(កំណើនសេដ្ឋកិច្ច)
- រួមចំណែកក្នុងការកាត់បន្ថយបន្ទុកផ្នែករដ្ឋាភិបាល និងតុលាការ
- ធ្វើឲ្យប្រសើរឡើងនូវទំនាក់ទំនងសង្គមនៅថ្នាក់មូលដ្ឋាន ។

# មេរៀនទី ២ សេដ្ឋកិច្ចតំបន់ និងការបែងចែកប្រភេទខេត្តក្រុង

## សំណួរ

1. ចូរកំណត់ន័យនៃពាក្យ " សេដ្ឋកិច្ច " ។
2. សេដ្ឋកិច្ចតំបន់ទំនាបកណ្ដាល រួមមានអ្វីខ្លះ ?
3. សេដ្ឋកិច្ចតាមខេត្តមួយចំនួនធំនៅកម្ពុជា មានលក្ខណៈដូចម្ដេច ?
4. តើបែងចែកប្រភេទខេត្តក្រុងនៅកម្ពុជា ដោយផ្អែកលើអ្វីខ្លះ ?
5. តើប្រទេសកម្ពុជា អាចមានសក្ដានុពលភាពសេដ្ឋកិច្ចលើផ្នែកអ្វីខ្លះ ?
6. សក្ដានុភាពនៅកម្ពុជាមានយ៉ាងដូចម្ដេចខ្លះ ?
7. ចូរនិយាយអំពីសក្ដានុពលភាព ផ្នែកទេសចរណ៍នៅកម្ពុជា ?

# ចម្លើយ

1.កំណត់ន័យនៃពាក្យ " សេដ្ឋកិច្ច " គឺជាសកម្មភាពផលិតកម្ម និងសេវាកម្មនានា ដែលកើតមានដោយផ្ទាល់នៅតាមតំបន់នីមួយៗ ។

2.សេដ្ឋកិច្ចតំបន់ទំនាបកណ្តាល រួមមាន ៖

- ការនេសាទតាមប្រព័ន្ធទន្លេសាប និងទន្លេមេគង្គ
- ដំណាំចម្ការតាមដងទន្លេសាបមានឈើហូបផ្លែ និងបន្លែបង្ការជាច្រើនមុខ
- គមនាគមន៍ និងការដឹកជញ្ជូនតាមផ្លូវទឹក ផ្លូវថ្នល់ ផ្លូវដែក ផ្លូវអាកាស
- ពាណិជ្ជកម្មតាមទីផ្សារនៅទីក្រុង ទីប្រជុំជន
- ក្រុមហ៊ុននាំចេញនាំចូល
- ទេសចរណ៍តាមរមណីដ្ឋាននានា ។

3.សេដ្ឋកិច្ចតាមខេត្តមួយចំនួនធំនៅកម្ពុជា មានលក្ខណៈជាសេដ្ឋកិច្ចចិញ្ចឹមពោះ បរិមាណផលដែលទទួលបានមានកម្រិតទាប ។

4.ការបែងចែកប្រភេទខេត្តក្រុងនៅកម្ពុជា ដោយផ្អែកលើសារៈសំខាន់សេដ្ឋកិច្ច និងចំនួនប្រជាជន ។

5.ប្រទេសកម្ពុជាអាចមានសក្តានុពលភាពសេដ្ឋកិច្ចលើផ្នែក កសិកម្ម និង ទេសចរណ៍ ។

សក្តានុភាពនៅកម្ពុជាមាន ៖

- តំបន់ដែលអនុគ្រោះខ្លាំងដល់ការងារស្រែចម្ការ
- តំបន់បញ្ចូលទឹកដែលអាចទាក់ទាញការវិនិយោគ និងអាចបន្សល់ផលសម្រាប់កែច្នៃនិង នាំចេញ ។

5. អំពីសក្តានុពលភាពផ្នែកទេសចរណ៍នៅកម្ពុជា

- សំបូរភោគទ្រព្យទេសចរណ៍( ទឹកជ្រោះ ទឹកធ្លាក់ ព្រៃភ្នំ សត្វព្រៃ )
- វប្បធម៌ប្រវត្តសាស្ត្រ និង កែច្នៃ ។

# មេរៀនទី៣ កំណើននគរូបនីយកម្ម និងបញ្ហាបរិស្ថាន

## សំណួរ

1. កំណត់និយមន័យនៃពាក្យ " កំណើននគរូបនីយកម្ម "
2. តើបញ្ហាបរិស្ថានដែលបណ្តាលមកពីកំណើននគរូបនីយកម្មមានអ្វីខ្លះ ? ចូររៀបរាប់ ។
3. ចូរនិយាយ ពីរបៀបគ្រប់គ្រងសំណល់រាវនៅទីក្រុងភ្នំពេញ។
4. ចូរនិយាយពីរបៀបទុកដាក់កាកសំណល់រឹងនៅប្រទេសយើង ។
5. តើការចាក់កាកសំណល់រឹងនៅកណ្តាលវាល បណ្តាលឲ្យមានគ្រោះថ្នាក់ដែរ ឬទេ ? ចូរពន្យល់ ។
6. តើអ្នកយល់ដូចម្តេច ចំពោះការទុកដាក់សំណល់រឹងនិងរាវ នៅកម្ពុជាសព្វថ្ងៃ ?

## ចម្លើយ

1. កំណត់និយមន័យនៃពាក្យ " កំណើននគរូបនីយកម្ម " គឺជាការរីកសាយនៃការរៀបចំ ការពង្រីក និងការបង្កបង្កើតទីក្រុង ។

2. បញ្ហាបរិស្ថានដែលបណ្តាលមកពីកំណើននគរូបនីយកម្មមានរួមមាន ៖

- កង្វក់អាកាស ដែលបណ្តាលមកពី ផ្សែងរោងចក្រម៉ាស៊ីនភ្លើង ផ្សែងចេញពីរថយន្តនិង ធូលីបណ្តាលមកពីផ្លូវថ្នល់មិនបានចាក់កៅស៊ូ
- ការរំខានដោយសូរសំឡេង ដែលចេញពីរោងចក្រម៉ាស៊ីនភ្លើង រថយន្ត និង ពេលមានពិធីបុណ្យ និងអាពាហ៍ពិពាហ៍ ។
- កាកសំណល់រាវ និង ប្រព័ន្ធលូទឹកស្អុយ ពុំទាន់មានរបៀបរាបរយ កាកសំណល់រាវចេញពីរោងចក្រមិនបានធ្វើប្រព្រឹត្តកម្មមុនពេលបញ្ចេញចោល ។ ប្រពន្ធ័លូចាស់មានភាពទ្រុឌទ្រោម ធ្វើឲ្យភ្លៀងហូរមិនទាន់ជូន ខ្ទុះចេញពីមាត់លូហូរចូលលំនៅឋានក៏មាន។

- ការគ្រប់គ្រងកាកសំណល់នៅទីក្រុង ការទុកដាក់កាកសំណល់ ពុំទាន់មានកន្លែងបានត្រឹមត្រូវនិងមានសណ្តាប់ធ្នាប់ល្អទេ ។
- បញ្ហាទឹកជំនន់ ដោយសារមានទំនប់ច្រើនជាន់នៅនៅទីក្រុងភ្នំពេញអាចជៀសផុតពីការគំរាមកំហែងនៃទឹកជំនន់បាន ប៉ុន្តែម្តងម្កាលពេលទឹកឡើងខ្លាំងវាបានធ្វើអោយប៉ះពាល់ដល់សំណង់ថ្មីៗ ពិសេសសំណង់អាណាធិប្បតេយ្យ នៅពេលមានការលើកទំនប់ដើម្បីការពារទឹកជំនន់ ។

3. និយាយពីរបៀបគ្រប់គ្រងសំណល់រាវនៅទីក្រុងភ្នំពេញគឺការបង្ហូរតាមបណ្តាញលូរកប់ក្នុងដី ឬ ប្រឡាយ យកទៅស្តុបទុកក្នុងអាងដែលជាបឹងធម្មជាតិ ។ បន្ទាប់មកគេបូមទឹកស្អុយទាំងនោះទំលាក់ចូលក្នុងទន្លេ ឬបឹងនានា ដោយមិនបានធ្វើប្រព្រឹត្តកម្មទឹកសំអុយនោះជាមុនទេ ។
4. និយាយពីរបៀបទុកដាក់កាកសំណល់រឹងនៅប្រទេសយើង ពុំទាន់មានកន្លែងសំរាប់ទុកដាក់សំណល់បាន

ត្រឹមត្រូវតាមបច្ចេកទេសវិទ្យាសាស្ត្រអ្វីទេ ហើយគេចាក់សំរាមកណ្ដាលវាល ។

5. ការចាក់កាកសំណល់រឹងនៅកណ្ដាលវាល បណ្ដាលឲ្យមានគ្រោះថ្នាក់យ៉ាងខ្លាំងដល់ប្រជាជនដែលរស់នៅតំបន់នោះដោយសារៈ

- ក្លិនអសោចិ៍នៃសំរាម
- ខ្យល់អាកាសមិនល្អបរិសុទ្ធ
- សំរាមបណ្ដាលឲ្យកើតមានសត្វរុយដែលជាភ្នាក់ងារចំលងជំងឺ
- សារធាតុពុលបង់សែន និង វិនីលក្លរីតភាយចេញពីការបំបែកធាតុជីវៈដែលបបណ្ដាលអោយមានជំងឺមហារីក ។

6. ចំពោះការទុកដាក់សំណល់រឹង និង រាវ នៅកម្ពុជាសព្វថ្ងៃ

- ពុំទាន់មានកន្លែងសំរាប់ទុកដាក់សំរាមឲ្យបានត្រឹមត្រូវទេ
- មិនទាន់បានរៀបចំទៅតាមបច្ចេកទេសវិទ្យាសាស្ត្រនៅឡើយទេ

- ការទុកដាក់សំរាមពុំទាន់មានរបៀបរាបរយ
- ពុំទាន់មានការធ្វើប្រព្រឹត្តកម្មទឹកសំអុយមុខពេលបង្ហូរចូលក្នុងទន្លេ បឹង ។

## សំណួរនិង ចម្លើយបញ្ចប់ជំពូកទី៤

**I. ចូរគូសសញ្ញា✓ ក្នុងប្រអប់ដែលមានចម្លើយត្រឹមតែមួយគត់**

1. ការសាងសង់ផ្លូវថ្នល់នៅក្នុងសម័យអាណានិគមនិយមបារាំង ប្រព្រឹត្តទៅដោយសារ

☑ក.ជំនួយអន្តរជាតិ

☐ខ.ជំនួយសេដ្ឋកិច្ចបារាំង

☐គ. កំណែនប្រជារាស្ត្រខ្មែរ

☐ឃ.កំណែនប្រជាជនឥណ្ឌូចិន

2. បើគិតពីកម្លាំងសេដ្ឋកិច្ច និងចំនួនប្រជាជនខេត្តកំពង់ធំត្រូវបានគេចាត់ទុកជា

☐ក. ខេត្តរឹងមាំ

☑គ.ខេត្តទន់ខ្សោយ

☐គ. ខេត្តមធ្យម

☐ឃ.ខេត្តខ្លាំងខាងទេសចរ

ii. ចូរបំពេញល្បះខាងក្រោមឲ្យបានត្រឹមត្រូវ

1. ការសាងសង់ទីក្រុងអង្គរជាភស្តុតាងបញ្ជាក់ច្បាស់ពីការងារផ្នែក...**ស្ថាបត្យកម្មគ្មានពី**...ដ៏ពិសិដ្ឋរបស់បុព្វបុរសខ្មែរ ។

2. ប៉ូលសេដ្ឋកិច្ចទាំងបីរបស់ប្រទេសកម្ពុជាសព្វថ្ងៃគឺភ្នំពេញ......**ខេត្តព្រះសីហនុ** ...និង...**ខេត្តសៀមរាប**...។

3. ខេត្តផ្សារភ្ជាប់ និងសេដ្ឋកិច្ចព្រំដែនមាន...**ខេត្តកោះកុង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ ស្វាយរៀង តាកែវ កណ្ដាល បាត់ដំបង មណ្ឌលគីរី រតនគីរី កំពង់ចាម**...... ។

4. អ្វីៗដែលនាំអោយប៉ះពាល់ដល់សោភ័ណក្រុងនិងមោទនភាពជាតិគឺ......**រថយន្តដែលដឹកជញ្ជូនសំរាមមានទឹកលេចចេញហៀរកត្តិកក្លាក់តាមផ្លូវ និង បានចោលក្លិនមិនល្អដល់អ្នកដំណើរ** ......។

iii. **សំណួរគន្លឹះ និង ចម្លើយ**

1. ចូលបង្ហាញឲ្យឃើញថា ដូនតាខ្មែរជំនាន់ដើមមានទេពកោសល្យខ្ពស់ ការរងារនគរូបនីយកម្ម ។

**ចម្លើយ** បង្ហាញឲ្យឃើញថា ដូនតាខ្មែរជំនាន់ដើមមានទេពកោសល្យខ្ពស់លើការងារនគរូបនីយកម្ម លោកចេះគ្រប់គ្រង និងរៀបចំដែនដី បង្កើតឲ្យមានភូមិ ឃុំ ស្រុក ខេត្ត ទីក្រុង រាជធានី គមនាគមន៍ កំពង់ផែ ដីស្រែចម្ការ សិប្បកម្ម និង ពានិជ្ជកម្ម ក្នុងនិង ក្រៅប្រទេស ។

2. ចូរនិយាយពីសារៈសំខាន់នៃ ការអនុវត្តគោលនយោបាយបែងចែកដីធ្លីសព្វថ្ងៃ ។

**ចម្លើយ** និយាយពីសារៈសំខាន់នៃ ការអនុវត្តគោលនយោបាយបែងចែកដីធ្លីសព្វថ្ងៃ

- នាំរកការកាត់បន្ថយភាពក្រីក្រដោយផ្ទាល់
- រួមចំណែកក្នុងការកាត់បន្ថយទិវាទដីធ្លី
- អាចឲ្យគេប្រើប្រាស់ដីនិងកម្លាំងពលកម្មដែលនៅទំនេរប្រកបដោយប្រសិទ្ធភាព(កំណើនសេដ្ឋកិច្ច)
- រួមចំណែកក្នុងការកាត់បន្ថយបន្ទុកផ្នែករដ្ឋភិបាល និងតុលាការ
- ធ្វើឲ្យប្រសើរឡើងនូវទំនាក់ទំនងសង្គមនៅថ្នាក់មូលដ្ឋាន ។

3. តើគេអាចរំដោះខេត្តតាមព្រំដែនមួយចំនួនឲ្យចេញផុតពីភាពដាច់ស្រយាលដោយមធ្យបាយណា ?

**ចម្លើយ** គេអាចរំដោះខេត្តតាមព្រំដែន មួយចំនួនឲ្យចេញផុតពីភាពដាច់ស្រយាលដោយមធ្យោបាយ ធ្វើការពង្រីកសកម្មភាពពាណិជ្ជកម្ម និង សេវាកម្មអោយមានភាពរស់រវើកធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធនៅតំបន់នោះមានភាពទំនើប

4. តើកម្ពុជាមានសក្តានុភាពសេដ្ឋកិច្ច លើផ្នែកអ្វីខ្លះនាពេលបច្ចុប្បន្ន ? ចូររៀបរាប់ ។

**ចម្លើយ** នៅពេលបច្ចុប្បន្នកម្ពុជាមានសក្តានុភាពសេដ្ឋកិច្ចលើ ផ្នែកកសិកម្មនិង ទេសចរណ៍ ។

**អំពីសក្តានុពលភាពផ្នែកកសិកម្ម**

- តំបន់ដែលអនុគ្រោះខ្លាំងដល់ការងារស្រែចម្ការ
- តំបន់បញ្ចូលទឹកដែលអាចទាក់ទាញការវិនិយោគ និងអាចបន្សល់ផលសម្រាប់កែច្នៃនិង នាំចេញ ។

**អំពីសក្តានុពលភាពផ្នែកទេសចរណ៍**

- សំបូរភោគទ្រព្យទេសចរណ៍( ទឹកជ្រោះ ទឹកធ្លាក់ ព្រៃភ្នំ សត្វព្រៃ )

▪ វប្បធម៌ប្រវត្តសាស្ត្រ និង កែច្នៃ ។

5. តើបញ្ហាបរិស្ថាន ដែលបណ្តាលមកពីកំណើននគរូបនីយកម្មមានអ្វីខ្លះ ? ចូររៀបរាប់ ។

**ចម្លើយ** បញ្ហាបរិស្ថានដែលបណ្តាលមកពីកំណើននគរូបនីយកម្មមានរួមមាន ៖

- កង្វក់អាកាស ដែលបណ្តាលមកពី ផ្សែងរោងចក្រ ម៉ាស៊ីនភ្លើង ផ្សែងចេញពីរថយន្តនិង ធូលីបណ្តាលមកពីផ្លូវថ្នល់មិនបានចាក់កៅស៊ូ
- ការរំខានដោយសូរសំឡេង ដែលចេញពីរោងចក្រ ម៉ាស៊ីនភ្លើង រថយន្ត និង ពេលមានពិធីបុណ្យ និង អាពាហ៍ពិពាហ៍ ។
- កាកសំណល់រាវ និង ប្រព័ន្ធលូទឹកស្អុយ ពុំទាន់មានរបៀបរាបរយ កាកសំណល់រាវចេញពីរោងចក្រមិនបានធ្វើប្រព្រឹត្តកម្មមុនពេលបញ្ចេញចោល ។ ប្រពន្ធ័លូចាស់មានភាពទ្រុឌទ្រោម ធ្វើឲ្យភ្លៀងហូរមិនទាន់ជួន ខ្ទុះចេញពីមាត់លូហូរចូលលំនៅឋានក៏មាន។
- ការគ្រប់គ្រងកាកសំណល់នៅទីក្រុង ការទុកដាក់កាកសំណល់ពុំទាន់មានកន្លែងបានត្រឹមត្រូវនិង

មានសណ្តាប់ធ្នាប់ល្អទេ ។

- បញ្ហាទឹកជំនន់ ដោយសារមានទំនប់ច្រើនជាន់នៅនៅទីក្រុងភ្នំពេញអាចជៀសផុតពីការគំរាមកំហែងនៃទឹកជំនន់បាន ប៉ុន្តែម្តងម្កាលពេលទឹកឡើងខ្លាំងវាបានធ្វើអោយប៉ះពាល់ដល់សំណង់ថ្មីៗ ពិសេសសំណង់អាណាធិប្បតេយ្យ នៅពេលមានការលើកទំនប់ដើម្បីការពារទឹកជំនន់ ។

6. តើអ្នកយល់ដូចម្តេច ចំពោះការទុកដាក់សំណល់រឹង និង រាវ នៅកម្ពុជាសព្វថ្ងៃ ?

**ចម្លើយ** ចំពោះការទុកដាក់សំណល់រឹងនិងរាវនៅកម្ពុជាសព្វថ្ងៃ

- ពុំទាន់មានកន្លែងសំរាប់ទុកដាក់សំរាមឲ្យបានត្រឹមត្រូវទេ
- មិនទាន់បានរៀបចំទៅតាមបច្ចេកទេសវិទ្យាសាស្ត្រនៅឡើយទេ
- ការទុកដាក់សំរាមពុំទាន់មានរបៀបរាបរយ
- ពុំទាន់មានការធ្វើប្រព្រឹត្តកម្មទឹកសំអុយមុខពេលបង្ហូរចូលក្នុងទន្លេ បឹង ។

# ជំពូកទី ៤ មជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចពិភពលោក

## មេរៀនទី ១ មជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចមួយ

### សំណួរ

1. ប្រព័ន្ធពិភពលោកមួយបានចាប់កំណើតឡើង ។ តើប្រព័ន្ធពិភពលោកនោះគឺជាអ្វី ?
2. តើអំណាចហិរញ្ញវត្ថុសំខាន់ៗមាននៅទីណាខ្លះ? ចូររៀបរាប់ ។
3. តើអំណាចហិរញ្ញវត្ថុ ដែលខ្លាំងគ្មានគូប្រៀបមាននៅទីណាខ្លះ ? ចូលរៀបរាប់ ។
4. អំណាចនៃការសម្រាចមាននៅទីណាខ្លះ ?ចូររៀបរាប់
5. តើគេអាចសំគាល់ថា ជាប៉ូលជំរុញសេដ្ឋកិច្ចមួយបានតាម រយៈអ្វី ?

### ចម្លើយ

1.នោះអំណាចហិរញ្ញវត្ថុ អំណាចនវកម្ម(ការបង្កើតថ្មី) នៃការសម្រាច ភាពម្ចាស់ការលើការដោះដូរនិងភ្ជុចនានា

បានដើរតួនាទីយ៉ាងសំខាន់បំផុតក្នុង សេដ្ឋកិច្ចពិភពលោក ។

2.អំណាចហិរញ្ញវត្ថុសំខាន់ៗមាននៅញូយ៉ក ឡុង និងតូក្យូ ។ ញូយ៉ក ជាមជ្ឈមណ្ឌលហិរញ្ញវត្ថុធំបំផុតក្នុងលោកជាទីផ្សារពិភពលោកដែលបើក 24ម៉ោង។ទីតាំងហិរញ្ញវត្ថុទីក្រុងតូក្យូទទួលបានការរីកចម្រើនអស្ចារ្យ ។ ទីក្រុងឡុង អាចឈរនៅជួរទីមួយបានដោយសារ ការបន្ធូរបន្ថយបទវិន័យនៃទីផ្សារភាគហ៊ុនការពីឆ្នាំ1985 ។

3.អំណាចហិរញ្ញវត្ថុ ដែលខ្លាំងគ្មានគូប្រៀបមាននៅស៊ីធីក្រុងឡុង វ៉ែលស្រ្ទីត នៅញូយ៉ក សង្កាត់ម៉ារូនូជី នៅតូក្យូ ។

4.អំណាចនៃការសម្រេច មាននៅក្នុងមជ្ឈមណ្ឌលមួយចំនួនដែលមានសិទ្ធនៃអឌ្ឍគោលខាងជើង ដែលជាអ្នករៀបចំចាត់ចែងលំហារពិភពលោក ។

5.គេអាចសំគាល់ថាជាប៉ូលជំរុញសេដ្ឋកិច្ចមួយបានតាមរយៈ ការប្រមូលផ្តុំមធ្យោបាយប្រមែប្រមូលព័ត៌មានទាំងឡាយ ។

# មេរៀនទី២ អំណោចសេដ្ឋកិច្ចពិភពលោក

## សំណួរ

1. តើទីក្រុងញូយ៉ករបស់សហរដ្ឋអាមេរិក បានបំពេញមុខងារអ្វីខ្លះ ?
2. តើម៉ិនហាថិន(Manhattan)ជាអ្វី ?ម៉ិនហាថិនចែកចេញជាប៉ុន្មានផ្នែក ។ ចូលនិយាយអំពីផ្នែកនីមួយៗ ។
3. ចូរនិយាយអំពីមុខងារជំរុញសេដ្ឋកិច្ចរបស់ទីក្រុងតូក្យូ
4. តើទ្វីអឺរ៉ុបមានប៉ូលជំរុញសេដ្ឋកិច្ចនៅទីណាខ្លះ ? ចូរនិយាយពីមុខងារជំរុញសេដ្ឋកិច្ចរបស់ទីក្រុងឡុង ។
5. តើតំបន់រ៉ាំង-រូ ស្ថិតនៅទីណា ? តើទីក្រុងសំខាន់ក្នុងតំបន់នោះមានឈ្មោះអ្វីខ្លះ ?
6. ចូលនិយាយអំពី មុខងារជំរុញសេដ្ឋកិច្ចរបស់តំបន់រ៉ាំងរូ ។
7. ចូរនិយាយអំពីមុខងារជំនុញសេដ្ឋកិច្ចរបស់តំបន់សាន់បែល របស់សហរដ្ឋអាមេរិក ។
8. តើទ្វីអឺរ៉ុបមានមជ្ឈមណ្ឌលបន្ទាប់បន្សំណាខ្លះ ? ចូររៀបរាប់ ។

9. តើប្រទេសកំពុងអភិវឌ្ឍមានមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចដែរឬទេ ? ចូរបង្ហាញ ។

10. តើភូមិវិទ្យាមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ច កកើតឡើងដោយផ្អែកលើមូលដ្ឋានអ្វីខ្លះ ?

## ចម្លើយ

1. ទីក្រុងញូយ៉ករបស់សហរដ្ឋអាមេរិកបានបំពេញមុខងារជាមជ្ឈមណ្ឌលពិភពលោកទីមួយ ជាបន្សំអនុភាពជាតិ និងអន្តរជាតិ មុខងារខាងឧស្សាហកម្ម និងមុខងារសេវាកម្ម ឲ្យដល់កម្រិតអន្តរជាតិ ។

2. ម៉ុនហាថិន(Manhattan) ជាមជ្ឈមណ្ឌលអង្គការសហប្រជាជាតិ ។ ម៉ុនហាថិនចែកចេញជា ពីរ ផ្នែក

- ប៉ែកខាងត្បូងមានដោនថោនដែលជាទីតាំងនៃទីផ្សារហាងឆេងញូយ៉កទីស្នាក់ការធានាគារអាមេរិកនិងធានាគារសំខាន់មួយចំនួន ។
- កណ្ដាលប៉ែកណ្ដាលនៃម៉ុហាថិន មានមីតថោនជា C.D.B ទី2 ធ្វើសកម្មភាពលើផ្នែក ទីស្នាក់ការធនាគារ

នានាប្រពន្ធ័ផ្សព្វផ្សាយពត៌មាន និងជាមជ្ឈមណ្ឌលវប្បធម៌ ។

3. និយាយអំពីមុខងារជំរុញសេដ្ឋកិច្ចរបស់ទីក្រុងតូក្យូ លើវិស័យរដ្ឋបាល ឧស្សាហកម្ម និង វប្បកម្ម ។ ឧស្សាហកម្ម ស្រូចស្រាលរបស់របស់ជប៉ុនចំនួនពាក់កណ្តាល ត្រូវបានសាងសង់ឡើង នៅតាមបរិមណ្ឌលទីក្រុងតូក្យូ ។ វាបានពង្រឹងប្រៀបខ្លាំង លើផ្នែកបច្ចេកទេសថ្មីនៃពត៌មាននិងគមនាគមន៍ ។

4. ទីអឺរ៉ុបមានប៉ូលជំរុញសេដ្ឋកិច្ចនៅទីក្រុងឡុង (ប្រទេសអង់គ្លេស) ទីក្រុងប៉ារី (ប្រទេសបារាំង) តំបន់រ៉ាំង-រូ ។និយាយពីមុខងារជំរុញសេដ្ឋកិច្ចរបស់ទីក្រុងឡុង បំពេញមុខងារខាងធនាគារ ហិរញ្ញវត្ថុ ធានារ៉ាប់រ៉ង ......។

5. តំបន់រ៉ាំង-រូ ស្ថិតនៅក្នុងប្រទេសអាឡឺម៉ង់។ទីក្រុងសំខាន់ក្នុងតំបន់នោះមានឈ្មោះ ទីក្រុងឌូសែលដហ្វ ។

6. និយាយអំពីមុខងារជំរុញសេដ្ឋកិច្ចរបស់តំបន់រ៉ាំង-រូ មានការបង្កើតជាកញ្ចុំក្រុងមួយដែលមានលក្ខណៈពហុប៉ូល។

7.និយាយអំពី មុខងារជំរុញសេដ្ឋកិច្ចរបស់តំបន់សាន់បែលរបស់សហរដ្ឋអាមេរិក ជាមជ្ឈមណ្ឌលនវកម្មនិងជាចំនុចប្រសព្វនៃគមនាគមន៍ ។

8.ទ្វីបអឺរ៉ុបមានមជ្ឈមណ្ឌលបន្ទាប់បន្សំនៅ អាំងស្វែដាំ នៅតំបន់រ៉េងស្ដាត-ហូឡង់ មីឡង់(អ៊ីតាលី) ឬ តំបន់ត្រីប៉ូលស៊ីស មានក្រុងសឺណោវ បាល និង ស៊ូរិច បច្ចុប្បន្នគឺមានថែមមួយទៀតលុចសំបួ ។

9.ប្រទេសកំពុងអភិវឌ្ឍគឺមានមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចដែរ។មានមេត្រូប៉ូលធំៗបានដើរតួជាមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចថ្នាក់ជាតិ ។ ប៉ុន្តែទីក្រុង **សៅប៉ូឡូ** របស់ប្រទេសប្រេស៊ីល និងទីក្រុង **ជោហានេសបួ** នៅទ្វីបអាហ្វ្រិបានបំពេញតួនាទីខ្នាតអន្តរជាតិដែរ ។

10.ភូមិវិទ្យាមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ច កកើតឡើងដោយផ្អែកលើមូលដ្ឋាន វឌ្ឍនភាពខាងដឹកជញ្ជូនដែលអាចផ្តល់ការផ្គត់ផ្គង់ថាមពលបានគ្រប់ទីកន្លែង រូបធាតុដើមមានតំលៃថោក និងដោយសារការវិវត្តផ្នែកទូរគមនាគមន៍ ។

# សំណួរ និង ចម្លើយបញ្ចប់ប្រយោគ

i. ចូលគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ទីក្រុងសំខាន់របស់ប្រទេសមួយ ឬតំបន់មួយ ដែលមានឥទ្ធិពលទៅលើទីក្រុងដទៃទៀតហៅថា

☑ក.ប៉ូលសេដ្ឋកិច្ច ☐ខ.មេត្រូប៉ូល

☐គ.មេកាប៉ូល ☐ឃ.មេកាឡូប៉ូល

2. ជោហានេសបួ (Johannesburg)ជាទីក្រុងសំខាន់មួយនៅ

☐ក.អាហ្វ្រិកខាងជើង ☐ខ.អាហ្វ្រិកកណ្តាល

☑គ.អាហ្វ្រិកខាងត្បូង ☐ឃ.អាហ្វ្រិខាងកើត

ii. ចូរបំពេញឃ្លាខាងក្រោមឲ្យបានត្រឹមត្រូវ

3. អំណាចហិរញ្ញវត្ថុគ្មានគូប្រៀប មាននៅម៉ារូនូជី(ជប៉ុន) វ៉ុលស្ទ្រីត(សហរដ្ឋអាមេរិក) និង...ស៊ីធីក្រុងឡុង... ។

4. តំបន់ត្រីប៉ូលស្វ៊ីសមានទីក្រុងបីគឺ បាល ...ក្រុងសឺណែវ និង...ស៊ូរិច....។

5.ត្រីប៉ូល(Triade)គឺជាប៉ូលជំរុញសេដ្ឋកិច្ចពីភពលោកទាំងបីមាន សហរដ្ឋអាមេរិក...**ជប៉ុន**...និង **អឺរ៉ុប** .......។

6.អចលនវត្ថុបញ្ញាប្រើសម្រាប់សម្គាល់ **សំណង់ដ៏អស្ចារ្យ** ដែលកើតមានជាបន្តបន្ទាប់នៅប្រទេសជប៉ុន ។

7. នៅទ្វីបអាស៊ីមានទីក្រុងបី ដែលបានសម្រេចជោគជ័យក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនគឺ ទីក្រុងសិង្ហបុរី.........**ហុងកុង**...និង.....**សេអ៊ូល**.....។

iii. **សំណួរត្រិះរិះ**

1. តើប្រព័ន្ធសេដ្ឋកិច្ចលោកគឺជាអ្វី ? ចូរពន្យល់ ?

ប្រព័ន្ធសេដ្ឋកិច្ចពិភពលោកគឺជា មេត្រូប៉ូលទាំងឡាយដែលក្នុងនោះអំណាចហិរញ្ញវត្ថុ អំណាចនវកម្ម(ការបង្កើតថ្មី) នៃការសម្រេច ភាពម្ចាស់ការដោះដូរ និងភ្លុចនានា ។

2. តើអំណាចហិរញ្ញវត្ថុ និង អំណាចនៃការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗមាននៅទីណាខ្លះ ? ចូររៀបរាប់ ?

អំណាចហិរញ្ញវត្ថុ និង អំណាចនៃការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗមាននៅក្នុងមេត្រូប៉ូល ៖ ធានាគារធំៗជាង

គេក្នុងពិភពលោក ចំនួន 50 ស្ថិតនៅភាយប៉ាយក្នុងទីក្រុងចំនួន 15 ទីក្រុងតូក្យូមាន12 ញូយ៉ក និងប៉ារីសមាន 5 និងទីក្រុងឡុងមាន 3 ។

3. តើទីក្រុងញូយ៉ករបស់សហរដ្ឋអាមេរិក បានបំពេញមុខងារ សេដ្ឋកិច្ចអ្វីខ្លះ ? ចូលបង្ហាញ ។

**ចម្លើយ** ទីក្រុងញូយ៉ករបស់សហរដ្ឋអាមេរិក បានបំពេញមុខងារជាមជ្ឈមណ្ឌលពិភពលោកទីមួយ ជាបន្សំអនុភាពជាតិនិងអន្តរជាតិ មុខងារខាងឧស្សាហកម្ម និងមុខងារសេវាកម្មឲ្យដល់កម្រិតអន្តរជាតិ ។

4. តើប្រទេសកំពុងអភិវឌ្ឍមានមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចដែរឬទេ ? ចូរពន្យល់ ។

ប្រទេសកំពុងអភិវឌ្ឍ គឺមានមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចដែរ ។ មានមេត្រូប៉ូលធំៗបានដើរតួជាមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចថ្នាក់ជាតិ ។ ប៉ុន្តែទីក្រុង **សៅប៉ូឡូ** របស់ប្រទេសប្រេស៊ីល និងទីក្រុង **ជោហានេសបួ** នៅទ្វីបអាហ្វ្រិចបានបំពេញតួនាទីខ្នាតអន្តរជាតិដែរ ។

5. តើគេអាចសំគាល់ថាជាប៉ូលជំរុញសេដ្ឋកិច្ចមួយបានតាមរយៈអ្វី ?

គេអាចសំគាល់ថា ជាប៉ូលជំរុញសេដ្ឋកិច្ចមួយបានតាមរយៈ ការប្រមូលផ្តុំមធ្យោបាយ ប្រមែប្រមូលព័ត៌មានទាំងឡាយ ។

6. តើភូមិវិទ្យាប៉ូលជំរុញសេដ្ឋកិច្ចបានដោយសារអ្វីខ្លះ ?ភូមិវិទ្យាប៉ូលបានជំរុញសេដ្ឋកិច្ចបានដោយសារ តែវឌ្ឍនភាពខាងការដឹកជញ្ជូន ដែលផ្តល់ការផ្គត់ផ្គង់ថាមពលបានគ្រប់ទីកន្លែង រូបធាតុដើមមានតំលៃថោកនិងដោយ សារការវិវត្តផ្នែកទូរគមនាគមន៍

# ជំពូកទី ៦ សហរដ្ឋអាមេរិក
## មេរៀនទី១ ប្រពន្ធ័សេដ្ឋកិច្ច រដ្ឋបាល និង នយោបាយសហរដ្ឋអាមេរិក

### សំណួរ

1. តើសេដ្ឋកិច្ចអាមេរិចផ្អែកលើគ្រឹះអ្វីខ្លះ ?
2. ដើម្បីពង្រីកទីផ្សារ តើសេដ្ឋកិច្ចអាមេរិចផ្អែកលើច្បាប់ ផ្សារដូចម្ដេចខ្លះ ?
3. ហេតុអ្វីបានជាសហគ្រាសតូចៗ និងកសិដ្ឋានត្រូវលោយ បាត់រូប ? ដើម្បីជំរុញការស្រាវជ្រាវរបៀបថ្មីៗ តើសប គ្រាសធំៗធ្វើយ៉ាងដូចម្ដេច ?
4. តើសហគ្រាសអាមេរិចឈានមុខគេ លើផ្នែកសកម្មភាព ខ្លះ ?
5. តើឧស្សាហកម្ម និងសេវាកម្មអ្វីខ្លះដែលល្បីល្បាយរាប ពាសពេញពិភពលោក ? ហេតុអ្វី ?
6. តើគេបង្កើតសហជីពដើម្បីអ្វី ?

តីរដ្ឋនីមួយៗនៃសហពន្ធ័មានអំណាចអ្វីខ្លះ ដើម្បីគ្រប់គ្រង ? ប្រធានាធិបតេយ្យមានអាណត្តិប៉ុន្មានឆ្នាំ ។ ហើយអាចឈរឈ្មោះ ឲ្យគេបោះឆ្នោតបានប៉ុន្មានដង ? តីរដ្ឋសហព័ន្ធ ធ្វើអន្តរាគមន៍ទៅលើបញ្ហាអ្វីខ្លះ ?

## ចម្លើយ

សេដ្ឋកិច្ចអាមេរិចផ្អែកលើគ្រឹះ

- សហគ្រាសសេរី ៖ សេរីភាពក្នុងការបង្កើតរោងចក្រសហគ្រាស
- ប្រកួតប្រជែងសេរី ៖ រោងចក្រសហគ្រាសមានសិទ្ធិប្រកួតប្រជែងគ្នាដោយសេរីលើផលិតកម្ម និងសេវាកម្ម ។
- បណ្តូរសេរី ៖ រោងចក្រសហគ្រាសអាចធ្វើការនាំចេញនាំចូលទំនិញដោយសេរី ពោលគឺជាប់ពន្ធតិចតួច ។

ដើម្បីពង្រីកទីផ្សារ សេដ្ឋកិច្ចអាមេរិចផ្អែកលើច្បាប់ទីផ្សារ ការពង្រីកទីផ្សារ តំរូវការនូវគំនិតច្នៃប្រឌិត និងផលិតភាពការងារខ្ពស់ ដើម្បីយកឈ្នះលើគូប្រជែង ។ បានជាសហគ្រាសតូចៗ និងកសិដ្ឋានត្រូវរលាយបាត់រូបដោយសារ ការលេបត្របាក់របស់ក្រុមហ៊ុនធំៗ ដែល

មានមូលធនដ៏ច្រើនសន្ធឹកសន្ធាប់ ។ ដើម្បីជំរុញការ ស្រាវជ្រាវរបៀបថ្មីៗ សហគ្រាសធំៗ បានផ្តល់ជំនួយ ឧបត្ថម្ភដ៏ច្រើនដល់មន្ទីពិសោធន៍នៃសកលវិទ្យាល័យ ទាំងនោះ ។

4. សហគ្រាសអាមេរិចឈានមុខគេ លើផ្នែកសកម្មភាព ឧស្សាហកម្ម និង សេវាកម្ម ។

5. ឧស្សាហកម្មនិង សេវាកម្មដែលល្បីល្បាយរាយពាស ពេញពិភពលោកមានដូចជា៖

ចំពោះឧស្សាហកម្ម ៖ កុំព្យូទ័រ និងផ្នែកពត៌មានវិទ្យា ឧបករណ៍បង្កើតពាក្យតូចៗក្នុងអវកាសផលិតផលឱសថ ជីវៈតិចណូឡូជី សម្ភារៈថ្មីៗនិងការស្រោចស្រង់បរិស្ថាន ។

ចំពោះសេវាកម្ម ៖ម៉ាក់ដូណាល់ ភីសាហ៊ុតឬខិនថឹកឃី ឈីខិន ។ ពីព្រោះពួកគេមានការស្រាវជ្រាវនិង អភិវឌ្ឍ បន្ថែមរហូតទៅលើវិស័យទាំងនឹង ។

6. គេបង្កើតសហជីពដើម្បីទុកធ្វើការចរចារជាមួយម្ចាស់ សហគ្រាសរដ្ឋនីមួយៗនៃសហពន្ធ័មានអំណាច នី ប្បញ្ញត្តិ នីតិប្រតិ

បត្តិ និងអំណាចតុលាការដើម្បីគ្រប់គ្រង ។ ប្រធានាធិប្បតេយ្យមានអាណត្តិ រយៈពេល 4 ឆ្នាំ ។ ហើយអាចឈរឈ្មោះ ឲ្យគេបោះឆ្នោតបានយ៉ាងច្រើនបានពីរដង ។

. រដ្ឋសហព័ន្ធ ធ្វើអន្តរាគមន៍ទៅលើបញ្ហាសេដ្ឋកិច្ចដូចជា ៖

- វិស័យគមនាគមន៍ ដំនឹកជញ្ជូនថាមពល និងកិច្ចការពារបរិស្ថាន។

# មេរៀនទី២ សហរដ្ឋអាមេរិកគ្រប់គ្រងលំហ

## សំណួរ

1. តើវិសាលភាពសហរដ្ឋអាមេរិក ផ្តល់សក្តានុពលភាពចំពោះវិស័យកសិកម្មដូចម្តេចខ្លះ ?
2. តើជួរភ្នំអាប៉ាឡាសមានសារៈសំខាន់សេដ្ឋកិច្ចយ៉ាងណាខ្លះ ?
3. តើអ្វីដែលជាកត្តាសំខាន់ សម្រាប់តំបន់ទំនាបកណ្តាលក្នុងវិស័យសេដ្ឋកិច្ច ?
4. ហេតុអ្វី បានជាភូមិភាគនិរតីនៃភាគខាងលិចក្លាយជាតំបន់ទេសចរណ៍ និងជាលំនៅឋានសម្រាប់និវត្តជន ?
5. គេចែកអាកាសធាតុនៅសហរដ្ឋអាមេរិកជាប៉ុន្មានផ្នែក ? អ្វីខ្លះ ?
6. តើការដឹកជញ្ជូនទំនិញតាមមធ្យោបាយណា ច្រើនជាងគេ ?
7. ហេតុអ្វី បានជាប្រជាជនអាមេរិកចូលចិត្តធ្វើដំណើរតាមផ្លូវថ្នល់ ។

8. ហេតុអ្វីបានជាសហរដ្ឋអាមេរិកសំបូរកំពង់ផែធំៗ ។

9. ហេតុអ្វី បានជាសកម្មភាពដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសមានការកើនឡើងចាប់ពីឆ្នាំ 1960មក ?

10. ចូលរៀបរាប់ពីភាពរីកចម្រើនផ្នែកព័ត៌មានវិទ្យារបស់សហរដ្ឋអាមេរិក ។

## ចម្លើយ

1. វិសាលភាពសហរដ្ឋអាមេរិក ផ្ដល់សក្ដានុពលភាពចំពោះវិស័យកសិកម្ម ភាពធំធេងនៃផ្ទៃដីសំរាប់ដាំដុះ និង ភាពសម្បូរបែបនៃធនធានធម្មជាតិ ។

2. ជួរភ្នំអាប៉ាឡាសមានសារៈសំខាន់សេដ្ឋកិច្ច ដូចជា៖
   - សំបូររ៉ែដែក ធ្យូងថ្ម ប្រេងកាត
   - ជាតំបន់ធារាសាស្ត្រសម្រាប់ផ្គត់ផ្គង់ដល់ ឧស្សាហានីយកម្មដែលសព្វថ្ងៃមានប្រហែល40 កន្លែង ។
   - សំបូររ៉ែមានតម្លៃជាច្រើន មានដូចជា អ៊ុយរ៉ាញ៉ូម ប្រាក់ មាស និង ប្រភពថាមពល ។

3. កត្តាសំខាន់សម្រាប់តំបន់ទំនាបកណ្តាល ក្នុងវិស័យសេដ្ឋកិច្ច មានដូចជា៖

- ភោគផលកសិកម្ម ៖ មានស្រូវពោត កប្បាស ស្រូវសាលី ចំការផ្លែឈើ បន្លែ និង ការចិញ្ចឹមសត្វជាលក្ខណៈកសិដ្ឋាន ។
- ភោគទ្រព្យធម្មជាតិ ៖ រ៉ែដែក ធ្យូងថ្ម ប្រេងកាត ឧស្ម័នធម្មជាតិ និងវារីអគ្គីសនី ។

4. បានជាភូមិភាគនិរតីនៃភាគខាងលិចក្លាយជាតំបន់ទេសចរណ៍ និង ជាលំនៅឋានសម្រាប់និវត្តជនដោយសារភាពសំបូរនៃពន្លឺព្រះអាទិត្យ ។
5. គេចែកអាកាសធាតុនៅសហរដ្ឋអាមេរិកជាបី ផ្នែក
   - អាកាសធាតុមហាសមុទ្រ
   - អាកាសធាតុស្ងួត
   - អាកាសធាតុកណ្ដាលទ្វីប ។

1. ការដឹកជញ្ជូនទំនិញតាមរថភ្លើងមានចំនួនច្រើនជាងគេ ។
2. បានជាប្រជាជនអាមេរិកចូលចិត្តធ្វើដំណើរ តាមផ្លូវថ្នល់ដោយសារ ផ្លូវថ្នល់មានការដឹកជញ្ជូនទំនិញតាមរថយន្តធំបានផ្ដល់ការងារជាច្រើន ដោយប្រើរយៈពេលតែ 4ថ្ងៃ ពីឆ្នេរអាត្លង់ទិក ទៅកាន់ឆ្នេរប៉ាស៊ីហ្វិក និង មានការចរាចរណ៍បានល្អ ។

3. បានជាសហរដ្ឋអាមេរិកសំបូរកំពង់ផែធំៗ ដោយសារ ការចរាចរណ៍ទំនិញនៅភាគឦសានតាមផ្លូវទឹកនិងជាកន្លែងសម្រាប់ប្តូរជ្រោះក្នុងប្រទេសនិងក្រៅប្រទេស ។
4. បានជាសកម្មភាពដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសមានការកើនឡើងចាប់ពីឆ្នាំ 1960មកដោយសារ តែមានអ្នកចំណូលស្រុកពីទ្វីបអាស៊ីនិង អាមេរិកឡាទីន និងក្រោយពីសង្គ្រាមនៅវៀតណាម វាមានអ្នកភៀសខ្លួនមកពីឥណ្ឌូចិនចូលមក ។
5. រៀបរាប់ពីភាពរីកចម្រើនផ្នែកព័ត៌មានវិទ្យារបស់សហរដ្ឋអាមេរិក ៖

- សំបូរមធ្យោបាយទំនើបបំផុតសំរាប់ផ្សព្វផ្សាយពត៌មានក្នុងប្រទេស
- ការប្រើប្រាស់ទូស័ព្ទចល័ត
- ការលូតលាស់នៃការផ្ញើសន្និសីទតាមទូរទស្សន៍ ។

# មេរៀនទី៣ ប្រជាជនសហរដ្ឋអាមេរិក

## សំណួរ

1. តើរបាយប្រជាជនសហរដ្ឋអាមេរិចមានលក្ខណៈដូចម្តេច? ចូលរៀបរាប់ ?
2. តើអ្នក ដែលមកតាំងទីដំបូងគេនៅសហរដ្ឋអាមេរិកមានឈ្មោះអ្វី ? ហេតុអ្វី បានជាពួកគេមានចំនួនតិចតួចនៅពេលបច្ចុប្បន្ន ?
3. តើចំណូលស្រុកជនជាតិអាស៊ី បានផ្តល់ផលប៉ះពាល់អ្វីខ្លះដល់សង្គមអាមេរិក ? ហេតុអ្វី ?
4. ហេតុអ្វី បានជាសហរដ្ឋអាមេរិកមានកំណើនប្រជាជនយឺត ?
5. សហរដ្ឋអាមេរិក ជាប្រទេសដែលមានកសិកម្មជឿនលឿន ។ ហេតុអ្វីបានជាវិស័យនេះប្រើប្រាស់កម្លាំងពលកម្មតិចម្ល៉េះ(2%) ?
6. តើពីរ៉ាមីតសហរដ្ឋអាមេរិកមានទម្រង់ចាស់ឬ ក្មេង ? ហេតុអ្វី ?

7. តើតំបន់ណាខ្លះមានទីក្រុងញឹកខ្លាំងមិនសូវញឹកខ្លាំង ?

8. តើមានមូលហេតុអ្វី ដែលធ្វើឲ្យរបាយប្រជាជនមិនស្មើគ្នា ?

9. ហេតុអ្វីបានជាតំបន់ខ្សែវង់ព្រះអាទិត្យមានការរីកចម្រើនឆាប់រហ័ស ។

10. តើជនជាតិភាគតិចណាខ្លះដែលរស់នៅក្នុងភាពក្រីក្រ ? ហេតុអ្វី ?

## ចម្លើយ

1. របាយប្រជាជនសហរដ្ឋអាមេរិច មានលក្ខណៈមិនស្មើគ្នាទេចាប់ពីរយៈបណ្ដោយ100 មកខាងកើតគេសង្កេតឃើញ ប្រជាជនរស់នៅកុះករជាពិសេសប៉ែកឥសាន្តនៃផ្ទៃប្រទេស ។ បន្ទាប់មកគេឃើញបណ្ដុំប្រជាជននៅប៉ែកខាងលិចតាមឆ្នេមហាសមុទ្រប៉ាស៊ីភិចចំនែកតំបន់កណ្ដាលពុំសូវមានមនុស្សរស់នៅទេ ។

2. អ្នកដែលមកតាំងទីដំបូងគេនៅសហរដ្ឋអាមេរិក គឺកុលសម្ព័ន្ធជនជាតិស្បែកក្រហម ។បានជាពួកគេមានចំនួនតិចតួចនៅ ពេលបច្ចុប្បន្នដោយសារសង្គ្រាមដឹកនាំ

ដោយពួកនិគមជនជាអ្នកត្រួសត្រាយ(ពួកស្បែក) ធ្វើការវាយដណ្ដើមយកភាគខាងលិច ។

3. ចំណូលស្រុកជនជាតិអាស៊ី បានធ្វើឲ្យផ្ដល់ផលប៉ះពាល់ដល់សង្គមសហរដ្ឋអាមេរិកដូចជា ៖

- ធ្វើឲ្យពួកគេពិបាករកការងារធ្វើឬ គ្មានការងារធ្វើ និង ទទួលបានប្រាក់បៀវត្សរ៍តិចតួច
- ជំនួញ ដីធ្លី ផ្ទះសំបែង មួយចំនួននៅក្នុងប្រទេសរបស់គេ ត្រូវពួកជនជនជាតិអាស៊ីកាន់កាប់។

នេះដោយសារ ៖

- ពួកគេយកបៀវត្សរ៍ស្ដួចស្ដើង
- កាន់កាប់ជំនួញតូចតាច និង ទិញដីធ្លី ផ្ទះសបែង ។

4. បានជាសហរដ្ឋអាមេរិកមានកំណើនប្រជាជនយឺតពីព្រោះ ៖

- កំណើនការងារនារី
- កំណើនភាពខ្វះការងារធ្វើ
- វិធីទប់ស្កាត់កុំឲ្យមានកូន ។

5. សហរដ្ឋអាមេរិកជាប្រទេសដែលមានកសិកម្មជឿនលឿន ។ បានជាវិស័យនេះប្រើប្រាស់កម្លាំងពលកម្មតិចម្ល៉េះ(2%) ដោយសារ ៖

- ការបំពាក់គ្រឿងយន្តមួយដល់អស្ចារ្យ
- ការបង្កើនអនុភាព នៃការស្រាវជ្រាវក្សេត្រសាស្ត្រជឿនលឿន
- ឯកទេសសកម្មតាមតំបន់(វង់កសិកម្ម) ដែលលែងមានលក្ខណៈដាច់ណាត់
- ផ្តល់លទ្ធិភាពឲ្យដល់ការដាំដុះដំណាំផ្សេងៗដ៏សំបូរបែបទាំងអស់នេះដែលជាហេតុធ្វើឲ្យវិស័យនេះប្រើប្រាស់កម្លាំងពលកម្មតិចម្ល៉េះ(2%) ។

6. ពីរ៉ាមីតសហរដ្ឋអាមេរិកមានទម្រង់ជាមនុស្សចាស់។ ពីព្រោះតែ ការរីកចម្រើនខាងសុខភាព វិសេសមកពីការចូលចិត្តធ្វើដំណើរកំសាន្តរបស់មនុស្សចាស់ ។

7. តំបន់ដែលមានទីក្រុងញឹកខ្លាំងមិនសូវញឹកខ្លាំងមាន

❖ តំបន់ទីក្រុងញឹកខ្លាំង

- តំបន់ឆ្នេរមហាសមុទ្រអាត្លង់ទិចមានទីក្រុងបុស្តុន ញូយ៉ក ហ្វីឡាដែលហ្វី បាលទីម័រវ៉ាស៊ីនតោនឌីស៊ី

❖ តំបន់មិនមានទីក្រុងញឹក

- ស្ថិតនៅភាគខាងត្បូង ផ្នែកខាងក្នុងប្រទេសដូចជា អាត្លង់តា ម៉ុមភីស ដាឡាស់សានអានតូនីញ៉ូ។

8.មានមូលហេតុដែលធ្វើឲ្យរបាយប្រជាជនមិនស្មើគ្នានេះបណ្តាលមកពី ៖

- មជ្ឈដ្ឋានធម្មជាតិ ដែលផ្តល់លក្ខណៈពិបាក ឬស្រួលរស់នៅ
- ប្រជាជនអាមេរិកចូលចិត្តចល័ត
- ការទៅរស់នៅតំបន់ទំនាញព្រះអាទិត្យដែលបង្កលក្ខណៈល្អដល់ការរស់នៅរបស់ពួកគេ ។

9.បានជាតំបន់ខ្សែវង់ព្រះអាទិត្យមានការរីកចម្រើនឆាប់រហ័សដោយសារ ៖

- ចំណូលស្រុកនៃពួកអាស៊ី និងម៉ិកស៊ិក
- អាកាសធាតុស្រួលរស់នៅសម្រាប់ពួកនិវត្តជន
- ជាតំបន់ទំនាញឧស្សាហកម្មធំៗ
- មានបច្ចេកវិទ្យាខ្ពស់
- មានសេវាកម្មផ្សេងៗជាច្រើន ។

10.ជនជាតិភាគតិច ដែលរស់នៅក្នុងភាពក្រីក្រមានពួក ស្បែកស អេស្ប៉ាញ ស្បែកខ្មៅ អាស៊ី ។ ដោយសារ ពួកគេ មានវណ្ណៈទាប ហើយទទួលបានកម្រៃតិច ធ្វើការមិនបាន គ្រប់ពេល មិនស្ថិតស្ថេរ ឬគ្មានការងារធ្វើ ។

# មេរៀនទី៤ លំហរសេដ្ឋកិច្ចសហរដ្ឋអាមេរិក

## សំណួរ

1. តើធនធានថាមពលសំខាន់ៗ របស់សហរដ្ឋអាមេរិកមានអ្វីខ្លះ ? មាននៅទីណាខ្លះ ?
2. តើសហគ្រាសសហរដ្ឋអាមេរិកប្រើយុទ្ធសាស្រ្តអ្វីខ្លះក្នុងការដោះស្រាយវិបត្តិ ?
3. តើឧស្សាហកម្មប្រពៃណីសហរដ្ឋអាមេរិកមានអ្វីខ្លះ ?
4. ចូរនិយាយអំពីស្ថានភាពឧស្សាហកម្មវាយនភ័ណ្ឌអាមេរិច ។
5. តើអ្វីទៅដែលហៅថាឧស្សាហកម្មបញ្ញា ? ហេតុអ្វីបានជាប្រទេសមហាអំណាចខិតខំប្រឹងប្រែងអភិវឌ្ឍវិស័យបញ្ញា ?
6. តើការបាត់បង់តុល្យភាពជញ្ជីងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក នាំឲ្យប៉ះពាល់ដល់ឧត្តមភាពរបស់ប្រទេសដែរឬទេ ? ចូរពន្យល់ ?

# ចម្លើយ

1. ធនធានថាមពលសំខាន់ ៗ របស់សហរដ្ឋអាមេរិកមាន ឧស្ម័នធម្មជាតិ ប្រេងកាត អ៊ីដ្រូកាបូ ធ្យូងថ្ម ។
2. សហគ្រាសសហរដ្ឋអាមេរិកប្រើយុទ្ធសាស្ត្រដើម្បីដោះស្រាយវិបត្តិ ៖
   - ផ្ទេរសកម្មភាពឧស្សាហកម្ម មួយចំណែកទៅប្រទេសកំពុងអភិវឌ្ឍន៍ ព្រោះនៅទីនោះតំលៃពលកម្មទាប
   - កាត់បន្ថយប្រាក់ឧបត្ថមរបស់កម្មករ
   - បញ្ចូលបច្ចេកវិទ្យាជាន់ខ្ពស់ទៅក្នុងផលិតកម្ម
   - បំលាស់ទីឧស្សាហកម្មមួយឆ្ពោះទៅភាគខាងត្បូងនៃប្រទេស ។
3. ឧស្សាហកម្មប្រពៃណីសហរដ្ឋអាមេរិកមាន៖
   - ឧស្សាហកម្មដែកថែប
   - ឧស្សាហកម្មសំនង់គ្រឿងយន្ត
   - ឧស្សាហកម្មវាយណាភណ្ឌ ។
4. និយាយអំពី ស្ថានភាពឧស្សាហកម្មវាយនភ័ណ្ឌអាមេរិច កាលពីដំបូងឧស្សាហកម្មនេះ បានតាំងទីនៅភូមិភាគឦសាន ឥឡូវបានផ្លាស់ទីឆ្ពោះទៅខាងត្បូង ដើម្បីស្វែង

រកហត្ថពលករ ដែលខ្វះជំនាញ និងមានតំលៃថោក ។

5. ដែលហៅថាឧស្សាហកម្មបញ្ញាគឺជា ឧស្សាហកម្មដែលប្រើដោយបញ្ញា ដែលផលិតមុខជំនាញដោយទាមទារក្រុមហត្ថពលករមានកម្រិតជំនាញខ្ពស់ ការស្រាវជ្រាវទុកជាមុន ការផ្សាំទៅនឹងបច្ចេកវិទ្យាចំឡែក និង មានការផ្លាស់ប្តូររហ័ស និង ជាប់ ជានិច្ច ។ បានជាប្រទេសមហាអំណាចខិតខំប្រឹងប្រែងអភិវឌ្ឍវិស័យបញ្ញា វាជាវិស័យមួយដ៏មានសារៈសំខាន់ ក្នុងការអភិវឌ្ឍប្រទេសប្រកបដោយនិរន្តភាព ពីព្រោះគ្រប់វិស័យទាំងអស់អាចរីកចំរើនទៅបានក៏ដោយសារវិស័យនេះដែរ ។

6. ការបាត់បង់តុល្យភាព ជញ្ជីងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកមិនបាន នាំឲ្យប៉ះពាល់ដល់ឧត្តមភាពរបស់ប្រទេសទេ ។ ពីព្រោះការទទួលបានផលចំណេញច្រើនពីការនាំចេញសេវា និង ការផ្ទេរមូលធនពីបរទេស ដែលនាំឲ្យជញ្ជីងទូរទាត់របស់គេអាចរក្សាតុល្យភាពបាន ។

# សំណួរ និង ចម្លើយបញ្ចប់ជំពូកទី៦

i. ចូលគូសសញ្ញា ✓ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1.សហរដ្ឋអាមេរិកមានរដ្ឋប៉ុន្មាន

☐ក.48 ☑ខ.50

☐គ.52 ☐ឃ.58

2.សកម្មភាពដឹកជញ្ជូនអ្នកដំណើរសំខានជាងគេគឺ

☐ក.ផ្លូវអាកាស ☐ខ.ផ្លូវដែក

គ.ផ្លូវថ្នល់ ☐ឃ.ផ្លូវទឹក

1.រដ្ឋដែលមានប្រជាជនរស់នៅច្រើនជាគេ

☑ក.ញូយ៉ក

☐ខ.កាលីហ្វ័រនី

☐គ.តិចសាស់

☐ឃ.ផ្លរីដា

i. ចូរបំពេញឈ្មោះខាងក្រោមឲ្យបានត្រឹមត្រូវ

ជួរភ្នំ ដែលស្ថិតនៅប៉ែកខាងកើតសហរដ្ឋអាមេរិកមានឈ្មោះថាជួរភ្នំ...អាបាឡាស......។

អាកាសយានដ្ឋានដែលធំនិងទទួលអ្នកដំណើរបានច្រើន

ជាងគេគឺអាកាសយានដ្ឋាន ...**អាត្លង់តា**......។

3. តំបន់ដែលពួកនិវត្តជនចូលចិត្តទៅរស់នៅគឺ **តំបន់វង់ព្រះអាទិត្យ**......។

**III.សំណួរ និង ចម្លើយ**

1.តើគ្រឹះសេរីភាពបុគ្គល ផ្តល់ផលល្អចំពោះសេដ្ឋកិច្ចអាមេរិកដូចម្តេចខ្លះ ?

**ចម្លើយ** គ្រឹះសេរីភាពបុគ្គលផ្តល់ផលល្អចំពោះសេដ្ឋកិច្ចអាមេរិកដូចជា ៖

- បង្កលក្ខណៈល្អចំពោះការពង្រឹងបុគ្គលភាព
- កម្មសិទ្ធិឯកជន អាចឲ្យមនុស្សម្នាក់ៗទាយផ្លែផ្កាការងារគេបាន ។

2.ហេតុអ្វីបានជាសហគ្រាសធំៗនៅអាមេរិក ផ្តល់ជំនួយឧត្តមដល់មន្ទីពិសោធន៍នៃសកលវិទ្យាល័យនានា ?

**ចម្លើយ** បានជាសហគ្រាសធំៗនៅអាមេរិក ផ្តល់ជំនួយឧត្តមដល់មន្ទីពិសោធន៍ នៃសកលវិទ្យាល័យនានា ពីព្រោះ សហគ្រាសធំៗ និងមន្ទីពិសោធន៍គឺមានទំនាក់ទំនងគ្នាយ៉ាងល្អក្នុងការបញ្ចូលនិងបង្កើតរបៀបថ្មី ។

តើសហគ្រាសធំៗនៅសហរដ្ឋអាមេរិក ស្ថិតក្នុងវិស័យឧស្សាហកម្មអ្វីខ្លះ ? ចូររៀបរាប់ឲ្យបានបួន ។

**ចម្លើយ** សហគ្រាសធំៗនៅសហរដ្ឋអាមេរិក ស្ថិតក្នុងវិស័យ ឧស្សាហកម្ម ៖

- វិស័យឧស្សាហកម្មថាមពល
- ឧស្សាហកម្មរថយន្ត
- ឧស្សាហកម្មអេឡិចត្រូនិច
- ឧស្សាហកម្មសេវា
- ឧស្សាហកម្មបរិក្ខាអគ្គិសនី ។

តើតំបន់ទំនាបកណ្តាល សហរដ្ឋអាមេរិកមានសារៈសំខាន់ចំពោះកសិកម្មដូចម្តេច ?

**ចម្លើយ** តំបន់ទំនាបកណ្តាលសហរដ្ឋអាមេរិកមានសារសំខាន់ចំពោះកសិកម្មដូចជា ៖

- មានដីមានជីជាតិសម្រាប់ដំណាំ
- មានទន្លេមីស៊ីស៊ីពីដែលបានហូរកាត់និង ជ្រៀមតំបន់ទំនាបកណ្តាល ។

តើការដឹកជញ្ជូនផ្នែកណា ដែលមានសកម្មភាពមមាញឹកជាងគេ ? ហេតុអ្វី ?

**ចម្លើយ** ផ្នែកដែលមានសកម្មភាពដឹកជញ្ជូនមមាញឹកជាងគេគឺផ្លូវដែកខាងដឹកជញ្ជូនទំនិញ ពីព្រោះ ផ្លូវដែកនោះវាកាត់ទ្វីភ្ជាប់តំបន់មហាសមុទ្រប៉ាស៊ីភិច ទៅមហាសមុទ្រអាត្លង់ទិក ។

6. ហេតុអ្វីបានជាសហរដ្ឋអាមេរិកក្លាយជាមហាអំណាចទី1 បើប្រទេសនេះទើបតែកើតមាន ?

**ចម្លើយ** បានជាសហរដ្ឋអាមេរិកក្លាយជាមហាអំណាចទី១បើប្រទេសនេះទើបតែកើតមានពីព្រោះ ៖

- វិសាលភាពនៃផ្ទៃដីកសិកម្មមានគ្រប់សណ្ឋាន
- អាកាសធាតុមានលក្ខណៈប្លែកៗគ្នា
- សំបូរធនធានមនុស្សឆ្លាត
- មានបច្ចេកទេសទំនើបៗនៅគ្រប់វិស័យ
- ផលិតភាពការងារ
- សំបូរធនធានរ៉ែ និង ព្រៃឈើ
- ជាប្រទេសមូលធននិយម ។

7. ហេតុអ្វីបានជាសហរដ្ឋអាមេរិកសំបូរទៅដោយចំណូលស្រុក ? ចាប់ពីឆ្នាំ 1960 តើចំណូលស្រុកច្រើនមកពីទ្វីបណាខ្លះ ? ហេតុអ្វី ?

**ចម្លើយ** បានជាសហរដ្ឋអាមេរិកសំបូរទៅដោយចំណូលស្រុកដោយសារតែ ប្រជាជនជាច្រើនមកពីប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនបានមកតាំងទីនៅទីនោះហើយបានធ្វើឲ្យសហរដ្ឋអាមេរិកបានទទួលផលល្អពីចំណូលស្រុកទាំងនោះទើបធ្វើឲ្យមានការបន្តចូលមកក្នុងប្រទេសជាច្រើន ។ ចាប់ពីឆ្នាំ 1960 គេឃើញមានចំណូលស្រុកច្រើនមកពីទ្វីបអាស៊ី និង អាមេរិកឡាទីន ។ ពីព្រោះមកពីសង្គ្រាមវៀតណាមបានបញ្ចប់ ។

8. អនុភាពកសិកម្មសហកម្មអាមេរិក ស្ថិតនៅចន្លោះឧត្តមភាពនិង ភាពចំនុះ ។ ចូរពន្យល់អំណះអំណាងនេះ ។

អនុភាពកសិកម្មសហកម្មអាមេរិក ស្ថិតនៅចន្លោះឧត្តមភាពនិង ភាពចំនុះ ពីព្រោះទីផ្សារអន្តរជាតិ ជាអាយុជីវិតនៃកសិកម្មអាមេរិក នៅពេលណាទីផ្សារលោកខាងត្បូង ឬ អឺរ៉ុបកាត់បន្ថយការបញ្ជាទិញ កសិករតែងជួបការលំបាកស្តុកកសិផលកាន់តែរីកធំ តំលៃផលិតផលស្រុតចុះ កសិករបង្ខំចិត្តលក់ស្រែចំការ ។

## ៧. លំហាត់ និង ចម្លើយ

1. នៅឆ្នាំ2009 សហរដ្ឋអាមេរិកមានប្រជាជន314659000 នាក់និងមានប្រជាជនទីក្រុង80% ។ ចូរគណនាចំនួនប្រជាជនរស់នៅជនបទ ?

**<u>ចម្លើយ</u>**

គណនាចំនួនប្រជាជនរស់នៅជនបទ

យើងដឹងថា ៖ ចំនួនប្រជាជនសរុប 314 659 000នាក់

ចំនួនប្រជាជនទីក្រុង 80%

គេបាន ៖

ចំនួនប្រជាជនទីក្រុង = 314 659 000 × 80%

= 251 727 200 នាក់

គេទាញបាន ៖

ចំនួនប្រជាជនរស់នៅជនបទ

= 314 659 000 – 251 727 200

= 62931800 នាក់

ដូចនេះ: ចំនួនប្រជាជនរស់នៅជនបទ 62931800 នាក់

2.នៅឆ្នាំ 2008 ប្រជាជនវ័យចាស់លើស 65ឆ្នាំមាន 13% 15ឆ្នាំមាន 20% ។ ចូរគណនាភាគរយនៃប្រជាជនសកម្ម ។

**ចម្លើយ**

គណនាភាគរយនៃប្រជាជនសកម្ម

យើងដឹងថា ៖ ប្រជាជនវ័យចាស់លើស 65 ឆ្នាំមាន 13% 15 ឆ្នាំមាន 20%

គេទាញបាន ៖ ភាគរយនៃប្រជាជនសកម្ម

$$100\% - (13\% + 20\%) = 67\%$$

ដូចនេះ: ចំនួនភាគរយនៃប្រជាជនសកម្មគឺ67%

## ជំពូកទី ៧ ប្រទេសជប៉ុន

## មេរៀនទី ១ គ្រឹះនៃមហាអំណាចជប៉ុន

### សំណួរ

1. តើគំនាបសង្កត់ ពីធម្មជាតិទៅលើប្រទេសជប៉ុនមានអ្វីខ្លះ ហេតុអ្វីបានជាប្រទេសជប៉ុន រងនូវបាតុភូតធម្មជាតិទាំងនោះ ?
2. ហេតុអ្វីបានជាបញ្ហាលើស ចំណុះប្រជាជនអាចដោះស្រាយបាននៅប្រទេសជប៉ុន ?
3. ហេតុអ្វី បានប្រទេសជប៉ុនស្ថិតក្នុងភាពចំណុះប្រទេសក្រៅ ?
9. ហេតុអ្វីបានជាប្រទេសជប៉ុនអាចការពារទីផ្សារក្នុងស្រុកបាន ?
10. ចូរកំណត់ន័យនៃពាក្យ " ទ្វិបនិយមសេដ្ឋកិច្ច " និង " ស្វូកូស្វូសា " ?
11. ចូរបង្ហាញពីគម្រូគ្រប់គ្រងសហគ្រាសតាមបែបជប៉ុន?

## ចម្លើយ

1. គ្រោះថ្នាក់ពីធម្មជាតិទៅលើប្រទេសជប៉ុនមានដូចជា៖
   - ផ្ទុះភ្នំភ្លើង
   - ព្យុះទីផុង
   - រញ្ជួយដី
   - រលកយក្សស៊ូណាមិ ។

   បានជាប្រទេសជប៉ុន រងនូវបាតុភូតធម្មជាតិទាំងនោះ ដោយសារប្រទេសជប៉ុនស្ថិតនៅលើកំរងកោះដែលមានសំបកដីស្តើង និងការវាតទីនៅលើសមុទ្រយកដី សាងសង់លំនៅឋាន សួនច្បារ ច្បារដំណាំ រោងចក្រឧស្សាហកម្ម តាមរបៀបធ្វើដី ខឿន ឬប៉ុលឌែ ។

2. បានជាបញ្ហាលើសចំណុះប្រជាជនអាចដោះស្រាយបាននៅប្រទេសជប៉ុនដោយសារ វឌ្ឍនភាពអាចស្រូបយកធនធានមនុស្សបានទាន់ពេល ហើយជនជាតិជប៉ុនមានលើលំហាតូចចង្អៀតបានប្រសើរជាង ពួកលោកខាងលិច ។

3. បានប្រទេសជប៉ុន ស្ថិតក្នុងភាពចំណុះប្រទេសក្រៅដោយសារតែ ភាពក្មេងខ្ចីនៃកំណាកំណើតទឹកដីដែលជា

កត្តានាំឲ្យខ្សត់ វត្ថុធាតុដើម និង ថាមពល ។

4. បានជាប្រទេសជប៉ុន អាចការពារទីផ្សារក្នុងស្រុកបាន ដោយសារ នៅប្រទេសជប៉ុនបើកាលណាមានក្តីបារម្ភ ចំពោះការប្រកួតប្រជែងពីបរទេស ប្រជាជនគេនឹងងាកមករកការប្រើប្រាស់ផលិតផលក្នុងស្រុកជានិច្ច ។

5. កំណត់ន័យនៃពាក្យ " ទ្វិបនិយមសេដ្ឋកិច្ច " និង

" សូកូសូសា" ទ្វិបនិយមសេដ្ឋកិច្ច គឺជាសហវិជ្ជមានរវាងសហគ្រាស

ធំៗ និង សហគ្រាសធនតូច និងធនមធ្យម PME នានា។

សូកូសូសា គឺជាសហគ្រាសពហុសេវា ។

បង្ហាញពីគម្រូគ្រប់គ្រងសហគ្រាសតាមបែបជប៉ុនមាន ៖

- រយៈពេលបំពេញការងារយូរ
- ធ្វើការបន្ថែមម៉ោងដោយមិនគិតកំរៃ
- ការឈប់សម្រាករយៈពេល 15 ថ្ងៃ ដោយប្តូរវេនគ្នាជាច្រើនដង
- អត្រាអវត្តមានកម្រិតទាប
- បៀវត្សមានកម្រិតខ្ពស់គ្រាន់បើ ប៉ុន្តែតំលៃជីភាពក៏ខ្ពស់ដែរ ។

# មេរៀនទី ២ ជប៉ុនដណ្តើមទីផ្សារពិភពលោក

## សំណួរ

1. ចំនុចខ្លាំងនៃឧស្សាហកម្មជប៉ុនចន្លោះឆ្នាំ 1950- 1973 មាន អ្វីខ្លះ ?
2. តើជប៉ុនដោះស្រាយវិបត្តិសេដ្ឋកិច្ចយ៉ាងដូចម្តេច?
3. ក្នុងការដោះស្រាយវិបត្តិសេដ្ឋកិច្ចជ ប៉ុនបានប្រើយុទ្ធសាស្ត្រអ្វីខ្លះ ?
4. តើឧស្សាហកម្មមូលដ្ឋានរបស់ជប៉ុនមានអ្វីខ្លះ?
5. តើឧស្សាហកម្មបញ្ញារបស់ជប៉ុនធ្វើសកម្មភាពលើផ្នែកអ្វីខ្លះ ?
6. តើឧស្សាហកម្មរថយន្តជប៉ុន ទទួលបានការរីកចម្រើនដូចម្តេចខ្លះ ? តើយុទ្ធសាស្ត្រឧស្សាហកម្មជប៉ុនដូចម្តេចខ្លះ ?
7. ហេតុអ្វីបានជាពាណិជ្ជកម្ម ជាតិជប៉ុនទទួលបានជោគជ័យ ?
8. ហេតុអ្វីបានជាការហូរចូលទំនិញបរទេស ចូលមកទីផ្សារក្នុងស្រុករបស់ជប៉ុនជួបការលំបាក ?

## ចម្លើយ

1. ចំនុចខ្លាំងនៃឧស្សាហកម្មជប៉ុនចន្លោះឆ្នាំ 1950 - 1973 មាន គឺការរីកដុះដាលនៃឧស្សាហកម្មដែលជាប់លំដាប់ថ្នាក់ពិភពលោក ។ ចាប់ពីឆ្នាំ 1950 រហូតដល់ 1973 សេដ្ឋកិច្ចជប៉ុនឈានដល់យុគនៃកំនើនបច្ចេកវិទ្យាទំនើបថ្មីៗ និងផលិតកម្មដ៏ច្រើនដែលមានឧស្សាហកម្មជាច្រើន ជួយជំរុញឲ្យ មានភាពល្វតលាស់ដូចជា ឧស្សាហកម្មដែកថែប ឧស្សាហកម្មសំណង់នាវា ។ ទន្ទឹមនេះក៏មានការរីកដុះដាល នៃឧស្សាហកម្មផលិតសម្ភារៈបរិក្ខារគ្រឿងឧបភោគ-បរិភោគ រថយន្ត គឺមីប្រេងកាត គ្រឿងអេឡិចត្រូនិច ។
2. ជប៉ុនដោះស្រាយវិបត្តិសេដ្ឋកិច្ចដោយ
   - រៀបចំឡើងវិញនូវឧបករណ៍ផលិតកម្ម
   - បង្កើនការនាំចេញលើការតាំងទីផលិតកម្មមួយចំនួន នៅក្រៅប្រទេស
   - ធ្វើការអភិវឌ្ឍទីផ្សារក្នុងស្រុក ។
3. ក្នុងការដោះស្រាយវិបត្តសេដ្ឋកិច្ច ជប៉ុនបានប្រើយុទ្ធសាស្ត្រលើបីចំណុច

- **ចំណុចទីមួយ ៖** បំបែករចនាសម្ព័ន្ធផលិតកម្មដោយផ្តោតការយោគចិត្តទុកដាក់ថ្មីទៅលើ PME ដែលអាចផ្សាំខ្លួន និងប្តូរសកម្មភាពបានឆាប់រហ័ស ។ ទន្ទឹមនេះគេក៏ពង្រឹងផ្នែកសេវាផងដែរ ។
- **ចំណុចទីពីរ ៖** គេធ្វើអន្តរជាតូបនីកម្មសេដ្ឋកិច្ចដ៏ធំទូលាយ បំផុតមួយ តាមរយៈការបង្កើតវិនិយោគនៅក្រៅប្រទេស ពិសេសលើផ្នែករថយន្ត យន្តបករណ៍ ឧបករណ៍អគ្គីសនី និងឧបករណ៍អេឡិត្រូនិច ។
- **ចំណុចទីបី ៖** គេបោះបង់ផ្នែកដែលទទួលបានការបញ្ហាទិញតិច ឬផ្នែកដែលប្រើប្រាស់ថាមពលខ្លាំង ផ្នែកដែលផ្តល់តម្លៃបន្ថែមទាបហើយ ដែលប្រទេសដទៃទៀតអាចផលិតបានដោយតម្លៃទាប ។

1. ឧស្សាហកម្មមូលដ្ឋានរបស់ជប៉ុនមាន សំណង់រថយន្ត នាវា ទូរស្សន៍ ម៉ាស៊ីនថតរូប និង មនុស្សយន្ត ។
2. ឧស្សាហកម្មបញ្ញារបស់ជប៉ុន ធ្វើសកម្មភាពលើផ្នែកគ្រឿងអេឡិចត្រូនិច រ៉ូបូទីច ( មនុស្សយន្ត ) ។
3. ឧស្សាហកម្មរថយន្តជប៉ុនទទួលបានការរីកចម្រើនយ៉ាងចំឡែក និងមានដំណើរប្រព្រឹត្តទៅយ៉ាងប្រសើរ ។ ការរីក